រាជបណ្ឌិត្យសភាកម្ពុជា

# ការអភិរក្សជីវៈចម្រុះ និង ការរស់នៅប្រកបដោយចីរភាពនៅតំបន់ឆ្នេរ

## ករណីសិក្សាក្នុងដែនជម្រកសត្វព្រៃពាមក្រសោប នៅខេត្តកោះកុង



រៀបចំដោយ៖ ផ្នែកបរិស្ថានធម្មជាតិ និង ជីវវិទ្យា

វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម

ខែមិថុនា ឆ្នាំ២០១៥

# ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាពនៅតំបន់ខ្មែរ

ករណីសិក្សាក្នុងដែនជម្រកសត្វព្រៃពាមក្រសោបនៅ

ខេត្តកោះកុង

**គណៈកម្មការនិពន្ធនិងស្រាវជ្រាវ**

១. លោកស្រីបណ្ឌិត ហ៊ិន សុទ្ធា
២. លោកបណ្ឌិត ទី និមល្ល
៣. លោក ហេង វីរិទ្ធិ
៤. លោកស្រី មុត សៅរ័ត្ន
៥. លោក រស់ ផាន្នី
៦. លោក ម៉ន វុត្ថា

**គណៈកម្មការត្រួតពិនិត្យ**

១. ឯកឧត្តមបណ្ឌិត ស៊ុន សុត
២. លោកបណ្ឌិត នុត សម្បត្តិ
២. លោកបណ្ឌិត ម៉ុង ស៊ាងងីម

**អក្សរាវិរុទ្ធ**

លោក រស់ ផាន្នី

**ឧបត្ថម្ភការស្រាវជ្រាវដោយ**

រាជបណ្ឌិត្យសភាកម្ពុជា

## មាតិកា

បញ្ជីតារាង រូបភាព និងក្រាហ្វិក..................................iii
បញ្ជីអក្សរកាត់..........................................................iv
សេចក្តីផ្តើម.............................................................១
១.ស្ថានភាពទូទៅនៃឆ្នេរសមុទ្រកម្ពុជា...........................៥
១.១.ស្ថានភាពទូទៅខេត្តកោះកុង....................................៧
១.១.១.ព្រំដែនរដ្ឋបាលខេត្តកោះកុង...................................៧
១.១.២. ធនធានធម្មជាតិខេត្តកោះកុង.................................៩
១.១.៣. ស្ថានភាពទូទៅឃុំពាមក្រសោប..........................១១
១.១.៤. ប្រវត្តិសហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប...
.............................................................................១៣
១.១.៥. ដែនជម្រកសត្វព្រៃពាមក្រសោប........................១៥
២. ស្ថានភាពជីវៈចម្រុះទូទៅនៅប្រទេសកម្ពុជា................១៨
៣. ស្ថានភាពជីវៈចម្រុះនៅខេត្តកោះកុង.........................២៥
៤. ប្រភេទជីវៈចម្រុះ និងការអភិរក្សនៅខេត្តកោះកុង.......២៧
៤.១. ប្រភេទជីវៈចម្រុះ.................................................២៨
៤.២. ការអភិរក្សជីវៈចម្រុះ.......................................... ៣៥
៤.២.១. ការរៀបចំកំណត់តំបន់អភិរក្ស..............................៣៥
៤.២.២. យុទ្ធសាស្ត្រនៃការអភិរក្សជីវចម្រុះ.........................៤០
៤.៣. បញ្ហាប្រឈមក្នុងដែនជម្រកសត្វព្រៃ..........................៤២

៥. ការរស់នៅ និងបញ្ហាប្រឈម.........................៤៨
៦. សន្និដ្ឋាន.................................................៥៤
ឧបសម្ព័ន្ធ
ឯកសារគន្ថនិទ្ទេស

# បញ្ជីតារាង រូបភាព និង ក្រាហ្វិក

## តារាង


តារាងទី១ .......................................................... ៣៩

តារាងទី២ ..........................................................៤០


## រូបភាព


រូបភាពទី១ ..........................................................៥

រូបភាពទី២ ..........................................................១០

រូបភាពទី៣ ..........................................................១០

រូបភាពទី៤ ..........................................................១៧

រូបភាពទី៥ ..........................................................១៧

រូបភាពទី៦ ..........................................................៣១

រូបភាពទី៧ ..........................................................៣១

រូបភាពទី៨ ..........................................................៤៣

រូបភាពទី៩ ..........................................................៤៧

រូបភាពទី១០ ..........................................................៥៣

រូបភាពទី១១ ..........................................................៥៣


## ក្រាហ្វិក


ក្រាហ្វិកទី១ ..........................................................១២

ក្រាហ្វិកទី២ ..........................................................១៣

## អក្សរកាត់

| | |
|---|---|
| CDC | : Council for the Development of Cambodia. |
| ICF | : International Crane Foundation |
| WCS | : World Church Service |
| WWF | : World Wildlife Fund |
| FFI | : Fauna and Flora International |
| IUCN | : International Union for Conservation of Nature |
| BI | : Bird International |

## សេចក្តីផ្តើម

ជីវៈចម្រុះ សំដៅទៅលើសារពាង្គកាយមានជីវិតទាំងអស់នៅក្នុងភពផែនដីដូចជា៖ រុក្ខជាតិ សត្វ ផ្សិត បាក់តេរី និង មីក្រូសារពាង្គកាយដទៃទៀត រួមទាំងប្រព័ន្ធអេកូឡូស៊ី និងដំណើរប្រព្រឹត្តទៅផ្សេងៗដែលរួមគ្នាជំរុញមុខងារជីវៈចម្រុះ។ បើតាមការបកស្រាយដែលមានក្នុងឯកសារបំណិនជីវិតស្តីពីបរិស្ថានរបស់ក្រសួងអប់រំ បានកំណត់និយមន័យជីវៈចម្រុះថា «ប្រភេទខុសៗគ្នាជាច្រើននៃជីវិតដែលរស់នៅក្នុងតំបន់ដូចគ្នា ឬផ្សេងៗគ្នានៅលើផែនដីដែលមានអន្តរអំពើជាមួយគ្នាទៅវិញទៅមក» (ក្រសួងអប់រំ, ២០១៣)។

ជីវៈចម្រុះ មានការប្រែប្រួលដោយសារឥទ្ធិពលនៃការប្រែប្រួលសេនេទិច និងដំណើរការវិវឌ្ឍន៍របស់វា ហើយក៏អាចថយចុះវិញដោយសារបញ្ហាផ្សេងៗដូចជា៖ ការរេចរឹលឬបាត់បង់ទីជម្រក ការបាត់បង់ប្រភេទជីវៈចម្រុះផ្សេងៗ និងការផុតពូជ។

អ្នកជំនាញផ្នែកសេដ្ឋកិច្ចបានទទួលស្គាល់ថា **ការថែរក្សាជីវៈចម្រុះបានគង់វង្ស អាចជានាបាននូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគត ជាពិសេសផ្នែកទេសចរណ៍ និងឧស្សាហកម្មឱសថ** ប៉ុន្តែការរក្សាមុខងារប្រព័ន្ធអេកូឡូស៊ីដើម្បីរក្សាលំនឹងជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីជាបញ្ហាលំបាក។ ជីវៈ

ចម្រុះ ចូលរួមចំណែកដល់ការធានានូវស្ថិរភាព និង និរន្តរភាព នៃបរិស្ថាន ពីព្រោះធនធានជីវសាស្ត្រ ជាធនធានកកើតឡើងវិញ។ រុក្ខជាតិ និង សត្វ ផ្តល់នូវផលិតផលខាងឧស្សាហកម្ម កសិកម្ម និង វេជ្ជសាស្ត្រ ព្រមទាំងស្បៀងអាហារ ដែលអាចជួយទ្រទ្រង់ដល់ជីវិតមនុស្ស និងប្រភេទដទៃទៀត (ក្រសួងបរិស្ថាន, ២០០៤)។

មជ្ឈមណ្ឌលត្រួតពិនិត្យការអភិរក្សពិភពលោក បានប៉ាន់ប្រមាណថា ប្រទេសកម្ពុជាមានរុក្ខជាតិចំនួន ១៥ ០០០ ប្រភេទខុសគ្នាៗ ដែលក្នុងនោះ ៩% ជាប្រភេទរុក្ខជាតិ ដែលមាននៅតែក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ (ក្រសួងបរិស្ថាន, ២០០៤) ។

តំបន់ព្រៃឈើ និង តំបន់ដីសើមព្រមទាំងជម្រកដទៃទៀតទ្រទ្រង់ដល់ប្រភេទសត្វ និង រុក្ខជាតិជាច្រើន។ គេជឿថា នៅប្រទេសកម្ពុជា មានប្រភេទថនិកសត្វប្រមាណជា ២១២ប្រភេទ បក្សីចំនួន ៧២០ប្រភេទ សត្វល្មូន (ឧរង្គសត្វ) ចំនួន ២៤០ ប្រភេទ និងរុក្ខជាតិមានសរសៃ មានលើសពី ២ ៣០០ប្រភេទ (Ashwell, 1994)។ ចំនួនត្រីប្រមាណ ៨៥០ប្រភេទ ត្រូវបានគេកត់សំគាល់ឃើញនៅក្នុងបឹងទន្លេសាប និង ទន្លេមេគង្គ ចំណែកនៅក្នុងសមុទ្រកម្ពុជាមានផ្កាថ្ម ស្មៅសមុទ្រ ព្រមទាំងត្រីនិងថនិកសត្វសមុទ្រប្រមាណ ៤៣៥ប្រភេទ (ក្រសួងបរិស្ថាន, ២០០៦) ។

ដោយឡែក «ដីសើមតំបន់ឆ្នេរ» ប្រទេសកម្ពុជាវិញ គឺជាស្ថានប្រព័ន្ធដ៏សម្បូរបែប មានដើមឈើយ៉ាងហោចណាស់ចំនួន ៧៤ប្រភេទ ហើយក៏ជាតំបន់ដែលសម្បូរដោយជីវៈចម្រុះច្រើនប្រភេទរស់នៅក្នុងតំបន់ព្រៃតាមតំបន់ឆ្នេរនៃប្រទេសកម្ពុជា។

ខេត្តកោះកុង ជាខេត្តមួយក្នុងចំណោមខេត្តទាំងបួន ស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រកម្ពុជា។ ខេត្តកោះកុង គ្របដណ្តប់ដោយព្រៃឈើច្រើនប្រភេទផ្សេងៗគ្នា ហើយក៏ជាទីសម្បូរដោយជីវៈចម្រុះជាច្រើនប្រភេទ។ ការតាំងទីលំនៅថ្មី និងលំហូរចូលអ្នកចំណូលស្រុកថ្មីមកដល់ខេត្តកោះកុង បានក្លាយជាក្តីបារម្ភដែលអាចបង្កការប៉ះពាល់ដល់ស្ថានប្រព័ន្ធ និងប្រភេទជីវៈចម្រុះដែលកំពុងរស់នៅតាមបណ្តោយឆ្នេរនៃខេត្តកោះកុង។ ទន្ទឹមគ្នានឹងការព្រួយបារម្ភចំពោះស្ថានភាពបរិស្ថាន ក៏ដូចជាជីវៈចម្រុះស្ថាប័នរដ្ឋនិងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានសហការនិងធ្វើការរួមគ្នា ដើម្បីការពារប្រភពធនធានធម្មជាតិដែលមានស្រាប់ទាំងនោះ។ តែទោះជាយ៉ាងណាក៏ដោយ មានទីជម្រកសត្វ និងប្រភេទសត្វជាច្រើន កំពុងរងការបំផ្លិចបំផ្លាញ និងប្រម៉ាញ់ដោយខុសច្បាប់។ ប្រភេទសត្វមួយចំនួន កំពុងរងគ្រោះខ្លាំងដែលអាចឈានដល់ការបាត់បង់ និង ផុតពូជពីតំបន់ឆ្នេរនៃខេត្តកោះកុងនេះ។

នៅឆ្នាំ១៩៩៣ ដែនជម្រកសត្វព្រៃពាមក្រសោប ត្រូវបានបង្កើតឡើងដោយក្រសួងបរិស្ថាន ដោយមានកិច្ចសហការ និងគាំទ្រពីសំណាក់អង្គការក្រៅរដ្ឋាភិបាល ក្នុងគោលបំណងសំខាន់អភិរក្សប្រភេទជីវៈចម្រុះដែលមានក្នុងដែនជម្រក។ តែទោះយ៉ាងណា ព័ត៌មានពីប្រភេទជីវៈចម្រុះ និងស្ថានប្រព័ន្ធក្នុងដែនជម្រកសត្វព្រៃពាមក្រសោប មិនទាន់មានការសិក្សាស្រាវជ្រាវឱ្យបានទូលំទូលាយនៅឡើយ។

ក្នុងការសិក្សាស្រាវជ្រាវនេះនឹងលើកយកករណីសិក្សាស្វែងយល់អំពីសកម្មភាពនៃការអភិរក្សជីវៈចម្រុះ ដែលមានក្នុងដែនជម្រកសត្វព្រៃពាមក្រសោប ព្រមទាំងសិក្សាទៅលើស្ថានភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងសហគមន៍ពាមក្រសោបនៃខេត្តកោះកុង។ ប្រភេទនៃជីវៈចម្រុះក្នុងដែនជម្រកសត្វព្រៃពាមក្រសោប ផែនការសកម្មភាពអភិរក្ស ដែលបានធ្វើ និងសកម្មភាពបន្ត បញ្ហាប្រឈមក្នុងការអនុវត្តផែនការសកម្មភាព ការលំបាក និងឧបសគ្គនានាចំពោះការរស់នៅរបស់ជីវៈចម្រុះ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់ឆ្នេរពិសេសក្នុងសហគមន៍ពាមក្រសោប នឹងត្រូវលើកយកមកធ្វើការសិក្សា និងពិភាក្សាពីទិដ្ឋភាពជាក់ស្តែង។ ក្រៅពីនេះ ដំណោះស្រាយ និងអនុសាសន៍មួយចំនួន នឹងត្រូវកំណត់បង្ហាញសម្រាប់

ជាប្រយោជន៍ដល់កិច្ចការពារប្រភេទជីវៈចម្រុះ ក្នុងតំបន់ឆ្នេរនៃខេត្តកោះកុង ក៏ដូចជាសម្រាប់តំបន់ឆ្នេរនៃប្រទេសកម្ពុជា។

## ១. ស្ថានភាពទូទៅនៃឆ្នេរសមុទ្រកម្ពុជា




រូបភាពទី ១៖ ព្រំដែនរដ្ឋបាលឆ្នេរសមុទ្រកម្ពុជា

ឆ្នេរសមុទ្រកម្ពុជា មានប្រវែងសរុបចំនួន ៤៣៥គម លាតសន្ធឹងតាមបណ្តោយឆ្នេរភាគឥសាន្ត នៃឈូងសមុទ្រថៃ

នៅចន្លោះប្រទេសវៀតណាម និងប្រទេសថៃ។ ឆ្នេរសមុទ្រកម្ពុជា គ្របដណ្តប់លើផ្ទៃដីសរុបប្រមាណពីចន្លោះចំនួន ១៧ ៧៩១គម² ទៅ ១៨ ៤៧៧គម² (Rizvi and Singer, 2011) និងស្ថិតក្នុងដែនដីនៃខេត្តចំនួនបួន មានដូចជា៖ ខេត្តកោះកុងជាប់ព្រំដែនប្រទេសថៃនៅភាគខាងលិច ខេត្តព្រះសីហនុ ខេត្តកំពតជាប់ព្រំដែនប្រទេសវៀតណាមនៅភាគខាងកើត និងខេត្តកែប។ ក្នុងដែនសមុទ្រកម្ពុជា មានកោះសរុបចំនួន ៦៤កោះ ក្នុងនោះរួមបញ្ចូលទាំងកោះនៅសមុទ្រក្រៅដូចជា៖ កោះតាង កោះព្រីង និងកោះពូឡូវ៉ៃ។

នៅតាមបណ្តោយឆ្នេរ មានស្ទឹងជាច្រើន បានហូរចុះនាំមកនូវកំទេចកំណរជាច្រើនចេញពីតំបន់ភ្នំ និង ទីចំណោតនានាដែលស្ថិតនៅក្បែរឆ្នេរសមុទ្រ។ ឆ្នេរសមុទ្រកម្ពុជា ជាទីប្រមូលផ្តុំនូវជម្រកសំខាន់ៗជាច្រើដូចជា៖ ឆ្នេរខ្សាច់ ពាម ខ្តបសមុទ្រ និង ផ្កាថ្ម ដែលជាទីជម្រកនៃប្រភេទជីវៈចម្រុះជាច្រើនប្រភេទ។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវមួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅឆ្នាំ១៩៩៩ បានបង្ហាញឱ្យដឹងថាតំបន់ឆ្នេរប្រទេសកម្ពុជា មានប្រជាជនរស់នៅតិចជាងគេបំផុតក្នុងអាស៊ីអាគ្នេយ៍ ហេតុនេះហើយព្រៃជម្រកសត្វនៅតាមឆ្នេរខ្សាច់ និងព្រៃកនានា ដូចជា៖ ព្រៃកោងកាង ព្រៃស្នាច់ ខ្តបសមុទ្រ ពាមជ្រូកក់ ផ្កាថ្ម និងស្មៅសមុទ្រ បានក្លាយជាទីជម្រក

ដែលបង្កលក្ខណៈងាយស្រួលដល់ការរស់នៅ និងបន្តពូជរបស់ជីវៈចម្រុះគ្រប់ប្រភេទ។

## ១.១. ស្ថានភាពទូទៅខេត្តកោះកុង

### *១.១.១. ព្រំដែនរដ្ឋបាលខេត្តកោះកុង*

ខេត្តកោះកុងស្ថិតនៅប៉ែកនិរតីនៃប្រទេស មានផ្ទៃក្រឡា ១០ ០៤៥គម² មានឆ្នេរប្រវែង ២៣៧គម² និងមានអាកាសធាតុមធ្យម២២,៥°C កំពស់ទឹកភ្លៀងប្រចាំឆ្នាំចន្លោះពី២ ០០០ ទៅ ៥ ២៦៨,៨៩មម/មួយឆ្នាំ។ ខេត្តកោះកុង មានប្រជាជនសរុបចំនួន ១០៧ ៤៨១នាក់ ក្នុងនោះប្រជាជនមានអាយុពី ១៥ទៅ៥៩ឆ្នាំ មានចំនួន ៦៩ ៨០៣នាក់ (ស្រី ៣៤ ៣៧៦ នាក់ ប្រុស ៣៥ ៤២៧នាក់) ដង់ស៊ីតេ១២នាក់ក្នុងមួយគីឡូម៉ែត្រការេ (CDC,២០១៥)[1]។

ខេត្តកោះកុង មានព្រំប្រទល់នៅភាគខាងជើងជាប់ខេត្តពោធិ៍សាត់ ភាគខាងកើតជាប់ខេត្តកំពង់ស្ពឺនិងខេត្តព្រះសីហនុ

---

[1] ព័ត៌មានលំអិតអំពីខេត្តកោះកុង សូមចូលគេហទំព័រក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)៖ http://www.cambodiainvestment.gov.kh/koh-kong-province.html

ភាគខាងត្បូងនិងខាងលិច ជាប់ឈូងសមុទ្រថៃ និងមួយផ្នែក ជាប់នឹងខេត្តត្រាតនៃប្រទេសថៃ។

ខេត្តកោះកុង បានផ្តាច់ចេញពីខេត្តកំពត តាមព្រះរាជក្រមលេខ ២៤ ន.ស. ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៥៨។ នៅឆ្នាំ២០០៨ ស្រុកកំពង់សិលា ដែលស្ថិតក្នុងដែនរដ្ឋបាលនៃខេត្តកោះកុង ក៏ត្រូវផ្តាច់ចេញ និងដាក់បញ្ចូលជាស្រុកចំណុះឱ្យខេត្តព្រះសីហនុ ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨។ ដូច្នេះបច្ចុប្បន្ន ខេត្តកោះកុង នៅមានស្រុកចំនួន ០៦ ក្រុងចំនួន០១ សង្កាត់ចំនួន០៣ ឃុំចំនួន២៦ និងភូមិចំនួន១១៦ ស្ថិតក្រោមចំណុះ (CDC,២០១៥)។

ខេត្តកោះកុង ជាតំបន់ដែលសម្បូរទៅដោយភ្នំ សមុទ្រ ទន្លេ ព្រែក និងកោះជាច្រើន។ តំបន់ទាំងនេះ ផ្តល់លក្ខណៈងាយស្រួល និងជាទីជម្រកដ៏ល្អសម្រាប់ការរស់នៅរបស់ជីវៈចម្រុះជាច្រើនប្រភេទ នៅខេត្តកោះកុង។ តែទោះយ៉ាងណា សកម្មភាពកាប់បំផ្លាញព្រៃឈើ និងការរានដីសម្រាប់សង់ទីលំនៅនិងធ្វើកសិកម្ម បានក្លាយជាកត្តាគំរាមកំហែងដល់ប្រភពធនធានធម្មជាតិ។ ហេតុនេះហើយ ទើបក្រសួងបរិស្ថាន បានចេញសេចក្តីប្រកាសបង្កើតដែនជម្រកសត្វព្រៃពាមក្រសោប ដែលស្ថិតក្នុងឃុំពាមក្រសោប ស្រុកមណ្ឌលសីមានៃខេត្តកោះកុង នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។ ការបង្កើត

ជាសហគមន៍ដែនជម្រក បានរួមចំណែកកាត់បន្ថយការបំផ្លាញដែនជម្រកសត្វព្រៃ ជួយការពារ និងអភិរក្សប្រភពធនធានធម្មជាតិ។

### *១.១.២. ធនធានធម្មជាតិនៃខេត្តកោះកុង*

ធនធានធម្មជាតិនៃខេត្តកោះកុង រាប់បញ្ចូលទាំងធនធានកោះ ធនធានក្នុងទឹក និងធនធានលើដី។ ខេត្តកោះកុងប្រមូលផ្តុំដោយប្រភេទត្រីសមុទ្រច្រើនប្រភេទ និងថនិកសត្វដែលជិតវិនាសផុតពូជជាច្រើនដូចជា៖ សត្វជ្រូកទឹក( Dugong) កន្ធាយ អណ្តើកសមុទ្រ ត្រីដុលហ្វីនជាដើម។ ក្រៅពីនេះ នៅមានពពួកផ្កាថ្ម និងស្មៅសមុទ្រជាច្រើនប្រភេទ ដែលជាប្រភពចំណីអាហារសំខាន់ សម្រាប់ហ្វូងមច្ឆជាតិសមុទ្រជាច្រើនទៀត តែទោះយ៉ាងណា ប្រភពធនធានទាំងនេះ មិនទាន់មានការស្រាវជ្រាវលំអិតកំណត់បង្ហាញឱ្យបានច្បាស់លាស់នៅឡើយទេ។ ចំណែកធនធានធម្មជាតិនៅលើដី មានព្រៃឈើជាច្រើនដែលគ្របដណ្តប់នៅលើទឹកដីនៃខេត្តកោះកុង ក្នុងនោះមានព្រៃកោងកាង ចំនួន ៦៣ ៧០០ហត ដែលជាទីជម្រករបស់សត្វគ្រប់ប្រភេទ (MoE, 2002)។



រូបភាពទី២ ៖ កោះសមុទ្រក្រៅ ថតនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥



រូបភាពទី៣៖ កោះអណ្តែតនៅតាតៃ ថតនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥

### ១.២.៣. ស្ថានភាពខ្ទរទៅឃុំពាមក្រសោប

ស្រុកមណ្ឌលសីមា ប្រមូលផ្ដុំដោយឃុំចំនួនបីគឺៈ ឃុំពាមក្រសោប ឃុំបាក់ខ្លង និងឃុំទួលគគីរ។ ឃុំពាមក្រសោបមានព្រំប្រទល់នៅភាគខាងជើងទល់នឹងដែនដីរដ្ឋបាលសង្កាត់ស្ទឹងវែង (ក្រុងខេមរភូមិន្ទ) ភាគខាងត្បូងទល់នឹងដែនដីរដ្ឋបាលឃុំកោះកាពិ (ស្រុកកោះកុង) ភាគខាងកើតទល់នឹងដែនដីរដ្ឋបាលឃុំទួលគគីរ និងភាគខាងលិចទល់នឹងដែនដីរដ្ឋបាលឃុំបាក់ខ្លង និងឈូងសមុទ្រ។

ឃុំពាមក្រសោបចែកជាពីរភូមិគឺៈ ភូមិ១ (ឬភូមិពាមក្រសោបចាស់) និងភូមិ២ (ឬភូមិបាងកាយ៉ាក)។ ឃុំនេះមានផ្ទៃដីសរុបទំហំ ៣ ១៦៤ហាត ក្នុងនោះមានព្រៃកោងកាងទំហំ១ ៣២៦ហាត និងផ្ទៃទឹកចំនួន ១ ៨២០ហាត។

តាមស្ថិតិឆ្នាំ២០១៥ពីសាលាឃុំពាមក្រសោបបានបង្ហាញថា ឃុំនេះមានប្រជាជនចំនួន ៣៣០គ្រួសារ និងមានប្រជាជនសរុបចំនួន ១ ៣៩៨នាក់ ក្នុងនោះមានស្ត្រីចំនួន៦៩៦នាក់ បុរសចំនួន ៧០២នាក់ បូករួមទាំងប្រជាពលរដ្ឋធ្វើចំណាក

ស្រុកចំនួន១០០នាក់[2]។




ក្រាហ្វិកទី១ ៖ ស្ថិតិប្រជាជនក្នុងសហគមន៍ពាមក្រសោប

មុខរបរសំខាន់ៗនៅក្នុងឃុំពាមក្រសោបនេះគឺ៖ របរនេសាទ (៦៧%) រត់ទូកដឹកភ្ញៀវទេសចរណ៍ (១៥%) លក់ដូរ (៨%) រត់ម៉ូតូឌុប (២%) លក់កម្លាំងពលកម្ម (៥%) និងជាមន្ត្រីរាជការ (៣%)[3]។

---

[2] រដ្ឋបាលឃុំពាមក្រសោប៖ របាយការណ៍ប្រចាំខែ ស្តីពី ការអនុវត្តការងាររបស់រដ្ឋបាល ឃុំសង្កាត់ទំព័រទី១ ខែ០៤ ឆ្នាំ២០១៥។

[3] លោកយ៉ែម យ៉ាន៖ បទបង្ហាញរបស់សហគមន៍តំបន់ការពារធម្មជាតិ និងនេសាទឃុំពាមក្រសោបទំព័រទី២ ថ្ងៃទី១៧ កញ្ញា ឆ្នាំ២០១០។




ក្រាហ្វិកទី ២៖ ប្រភេទការងារក្នុងសហគមន៍ពាមក្រសោប

### *១.១.៤. ប្រវត្តិសហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប*

មុនឆ្នាំ២០០១ ឃុំពាមក្រសោបជួបប្រទះបញ្ហាជាច្រើន ដែលជាមូលហេតុយ៉ាងសំខាន់ ធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍ ឃុំ ហើយក៏ជាមូលហេតុធ្វើឱ្យបាត់បង់ប្រភពធនធានធម្មជាតិ និងប្រភេទជីវៈចម្រុះជាច្រើន។ បញ្ហាទាំងនោះមានដូចជា៖ ការកាប់បំផ្លាញព្រៃកោងកាង បញ្ហាប្រជាជនចំណូលស្រុក ការយល់ដឹងតិចតួចពីសារៈប្រយោជន៍ព្រៃកោងកាង ការថយចុះធនធានជលផល កង្វះដីសង់លំនៅដ្ឋាននិងដីធ្វើស្រែចំការ ការបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា និងកង្វះខាតមធ្យោបាយជូនអ្នកជំងឺទៅមន្ទីរពេទ្យជាដើម។ បញ្ហាទាំងនេះ

បានជំរុញឱ្យឃុំពាមក្រសោប បង្កើតសហគមន៍តំបន់ការពារធម្មជាតិ និងនេសាទ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០១[4]។

ការបង្កើតសហគមន៍នេះ ផ្តល់អត្ថប្រយោជន៍ជាច្រើនជួយដល់សហគមន៍ ក្នុងការរៀបចំនូវផែនការសកម្មភាពរបស់ខ្លួន ទប់ស្កាត់ការបំផ្លាញ និងអភិរក្សនូវប្រភពធនធានធម្មជាតិ ទីជម្រក និងប្រភេទជីវៈចម្រុះជាច្រើន។ ភ្នាក់ងារ និងបណ្តាញជាច្រើនត្រូវបង្កើតឡើង ដោយមានការសហការជាមួយអាជ្ញាធរដែនជម្រកសត្វព្រៃពាមក្រសោប ដែលមានទីតាំងក្នុងសហគមន៍សម្រាប់យាមល្បាតការពារដែនសហគមន៍ ទប់ស្កាត់ការកាប់បំផ្លាញព្រៃកោងកាង បង្ក្រាបការធ្វើឡធ្យូងជាដើម។ ក្រៅពីនេះ ស្ថានីយ៍បណ្តុះដើមកោងកាង បានចូលរួមចំណែកយ៉ាងសំខាន់ ជួយគាំទ្រដល់សកម្មភាពដាំព្រៃកោងកាងឡើងវិញ សម្រាប់ជាប្រយោជន៍ដល់ដែនជម្រកសត្វព្រៃពាមក្រសោប និងសហគមន៍។

---

[4] លោក វង្ស តារា ៖ បទបង្ហាញសហគមន៍តំបន់ការពារធម្មជាតិពាមក្រសោបទំព័រទី៣ ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤។

### ១.១.៥. ដែនជម្រកសត្វព្រៃពាមក្រសោប

ដែនជម្រកសត្វព្រៃពាមក្រសោប គឺជាតំបន់មួយក្នុងចំណោមតំបន់ការពារជាច្រើននៅក្នុងប្រទេសកម្ពុជា ដែលកំពុងទទួលបានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានា ហើយតំបន់នេះក៏សម្បូរនូវប្រភេទព្រៃកោងកាងច្រើនជាងគេគួរឱ្យកត់សម្គាល់នៅតំបន់ឆ្នេរនៃតំបន់អាស៊ីអាគ្នេយ៍នេះ។ នៅក្នុងដែនជម្រកសត្វព្រៃនេះសំបូរដោយទីជម្រកដ៏ប្រសើរ សម្រាប់ការរស់នៅរបស់ជីវៈចម្រុះជាច្រើនប្រភេទដែលកំពុងទទួលរងការគំរាមកំហែង និងអាចឈានទៅរកការបាត់បង់នៅទីកន្លែងដទៃក្នុងពិភពលោក (An et al., 2009)។

នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលបានសម្រេចចេញរាជក្រឹត្យ បង្កើតដែនជម្រកសត្វព្រៃពាមក្រសោបស្ថិតនៅភាគត្បូងឈាងខាងលិចនៃខេត្តកោះកុង លើផ្ទៃដីទំហំ ២៣ ៧៥៩ហ.ត.។ មកដល់ឆ្នាំ២០០៣ ក្រសួងបរិស្ថាន ក្រសួងដែនដីនគររូបនីយកម្ម និងអាជ្ញាធរខេត្តកោះកុង បានធ្វើការអភិវឌ្ឍនិងពង្រីកដែនជម្រកសត្វព្រៃពាមក្រសោបដល់ ២៥ ៨៩៧ហ.ត.។

ដែនជម្រកសត្វព្រៃពាមក្រសោប គ្របដណ្តប់លើភូមិចំនួន១៣ភូមិ ក្នុងស្រុកចំនួនបីគឺ៖ ស្រុកមណ្ឌលសីមា (ឃុំពាមក្រសោប ឃុំបាក់ខ្លង ឃុំទួលគគីរ) ស្រុកកោះកុង (ឃុំកោះកាពិ ឃុំតាតៃ) និងក្រុងខេមរភូមិន្ទ (សង្កាត់ស្ទឹងវែង) និងមានប្រជាជនរស់នៅសរុបប្រមាណជា ១០ ០០០នាក់។ ដែនជម្រកសត្វព្រៃពាមក្រសោប សម្បូរដោយព្រៃស្រោង ស្ទឹង តំបន់ទឹកធ្លាក់ តំបន់ឆ្នេរសមុទ្រ តំបន់ព្រៃលិចទឹក និងកោះជាច្រើន។

ភាពសម្បូរបែបនៃប្រភពធនធានធម្មជាតិក្នុងដែនជម្រកសត្វព្រៃពាមក្រសោប បានទាក់ទាញជនចំណូលស្រុកជាច្រើនមកស្វែងរកផលប្រយោជន៍ពីធម្មជាតិ និងមកតាំងទីលំនៅថ្មី។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ តំបន់ព្រៃកោងកាង ជាទីជម្រកសត្វ បានរងការបំផ្លិចបំផ្លាញជាដំណំធ្វើជាអុសផ្សង អុសដុត ការបង្កើតកសិដ្ឋានចិញ្ចឹមបង្គារ និងការតាំងទីលំនៅថ្មី។ សកម្មភាពទាំងនេះ រួមផ្សំជាមួយនឹងការកាប់ឈើខុសច្បាប់ ការធ្វើអាជីវកម្មហួសកម្រិត ប្រម៉ាញ់ នេសាទនិងការទន្ទ្រានដី បានក្លាយជាមូលហេតុចម្បងបំផុតនៃការថយចុះប្រភេទជីវៈចម្រុះក្នុងដែនជម្រកសត្វព្រៃពាមក្រសោបកន្លងមក (An et al., 2009)។



រូបភាពទី៤៖ កិច្ចសម្ភាសរវាងក្រុមការងារ ជាមួយថ្នាក់ដឹកនាំឃុំពាម
ក្រសោប ថ្ងៃទី២៧ខែមេសា ឆ្នាំ២០១៥




រូបភាពទី៥៖ ថតរូបអនុស្សាវរីយ ជាមួយក្រុមប្រឹក្សាឃុំពាមក្រសោប
ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥

## ២. ស្ថានភាពជីវៈចម្រុះទូទៅនៅប្រទេសកម្ពុជា

ទោះបីជាប្រទេសកម្ពុជាមានទីជម្រកសត្វ និងរុក្ខជាតិមួយចំនួនមិនទាន់ប៉ះពាល់នៅឡើយ ហើយមានប្រភេទសត្វខ្លះបានផុតពូជនៅប្រទេសជិតខាងក៏ដោយ ក៏កម្ពុជានៅមានទីជម្រកសត្វ រុក្ខជាតិ និងប្រព័ន្ធអេកូផ្សេងៗមួយចំនួន កំពុងរងគ្រោះជាបន្តបន្ទាប់។

ការបរបាញ់ ការដាក់អន្ទាក់ និងការចាប់សត្វព្រៃ កើតមានឡើងមួយផ្នែកដោយសារតែការជួញដូរប្រភេទសត្វកម្រខុសច្បាប់ទៅក្រៅប្រទេស និងតម្រូវការរបស់ប្រជាជននៅជនបទក្នុងការរកប្រាក់ចំណូលឬជាអាហារបន្ថែម។ ការសិក្សាអង្កេតជាច្រើនបានបង្ហាញថា សកម្មភាពចាប់សត្វព្រៃដែលបានលើកឡើងខាងលើទាំងក្នុង និងក្រៅតំបន់ការពារ បង្កជាការគំរាមកំហែងយ៉ាងខ្លាំងចំពោះជីវៈចម្រុះនៅក្នុងប្រទេសកម្ពុជា ( Hout et al., 2003; Smith, 2001 )។

ការបាត់បង់ទីជម្រក ដោយសារអាជីវកម្មព្រៃឈើគ្មាននិរន្តរភាព ការពង្រីកផ្ទៃដីកសិកម្ម និងការរានដីព្រៃយកធ្វើជាកម្មសិទ្ធក៏ជាមូលហេតុបណ្តាលឱ្យមានការថយចុះនូវបរិមាណសត្វព្រៃដែរ។

កង្វះខាតការរៀបចំផែនការគ្រប់គ្រង និងការអនុវត្តច្បាប់ រួមជាមួយនឹងកំណើនប្រជាជន ២,៤% ប្រចាំឆ្នាំ នឹងបន្តជាស់ ពាធបន្ថែមទៅលើប្រព័ន្ធធម្មជាតិ។ ប្រសិនបើពុំមានវិធាន ការណ៍តឹងរឹង ប្រភពធនធានធម្មជាតិនៅប្រទេសកម្ពុជា នឹងត្រូវ រងការបាត់បង់ ពិសេសឱកាសបង្កើតតំបន់ទេសចរណ៍ធម្មជាតិ និងអត្ថប្រយោជន៍ពីឧស្សាហកម្មព្រៃឈើ (ក្រសួងបរិស្ថាន ២០០៤)។

ការកាត់បន្ថយភាពក្រីក្រ គឺជាអាទិភាពចំបងរបស់រាជ រដ្ឋាភិបាល ដែលត្រូវការការអភិវឌ្ឍប្រកបដោយតុល្យភាព និង មានផែនការត្រឹមត្រូវ ដើម្បីធានាការពារផលប្រយោជន៍ដល់ ជនក្រីក្រក្នុងសហគមន៍។ ដំណើរការនេះ ធ្វើឱ្យមានការប្រែ ប្រួលទំហំ និងគុណភាពទីជម្រកដោយមិនអាចជៀសផុត។ ហេតុនេះការអភិវឌ្ឍនៅក្នុងវិស័យផ្សេងទៀត ដែលមិនទាក់ទង នឹងជីវៈចម្រុះដូចជា៖ វិស័យឧស្សហកម្ម សេវាកម្ម និងការ អភិវឌ្ឍទីក្រុង អាចជួយកាត់បន្ថយសម្ពាធទៅលើធនធានធម្ម ជាតិដែលមាននាពេលបច្ចុប្បន្ន។

គោលនយោបាយសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងជីវៈ ចម្រុះ ត្រូវរាជរដ្ឋាភិបាលលើកឡើង ជាពិសេសច្បាប់ភូមិបាល ច្បាប់ព្រៃឈើ និងបទដ្ឋានច្បាប់ផ្សេងៗទៀត។ បើទោះជាមិន ទាន់មានព័ត៌មាន និងទិន្នន័យស្តីពីស្ថានភាពមរតកជីវសាស្ត្រ

១៨ប្រភេទ ក្នុងរយៈពេល៦ឆ្នាំកន្លងមកនេះ (Smith, 2001)។ នៅឆ្នាំ២០០១ ការសិក្សាពីថនិកសត្វសមុទ្រនៅឆ្នេរប្រទេសកម្ពុជា បានបន្ថែមប្រភេទត្រីបាឡែនថ្មីចំនួន ៦ប្រភេទទៀតទៅក្នុងបញ្ជីថនិកសត្វសមុទ្រ និងកើនចំនួនខ្ពស់ជាងប្រភេទសត្វផ្សោតនៅក្នុងដែនទឹកប្រទេសជិតខាង (ប្រទេសថៃ និងវៀតណាម)។ មកទល់សព្វថ្ងៃនេះ ក្នុងចំណោមប្រភេទថនិកសត្វដីគោក ដែលបានចុះបញ្ជីអង្គការ IUCN មាន៣៥ ប្រភេទ ដែលគេបានរកឃើញក្នុងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវ និងសិក្សាអង្កេតបន្ថែមជាតម្រូវការចាំបាច់ ដើម្បីឱ្យដឹងច្បាស់អំពីថនិកសត្វនៅក្នុងប្រទេសកម្ពុជា (ក្រសួងបរិស្ថាន ២០០៦) ។

## ខ.ប្រភេទសត្វស្លាប

ប្រទេសកម្ពុជា នៅមានទជម្រកធម្មជាតិល្អៗ ដែលអាចជួយទ្រទ្រង់ជីវិតសត្វស្លាបជាច្រើន។ សត្វស្លាបចំនួន ៥៣០ ប្រភេទត្រូវបានកត់ត្រាហើយ ប្រភេទសត្វស្លាបសរុបអាចមានចំនួនច្រើនជាងនេះទៀត (Houtetal.,2003)។ មិនតែប៉ុណ្ណោះ ប្រភេទសត្វស្លាបទឹក ដែលទទួលរងការគំរាមគំហែងជាលក្ខណៈអន្តរជាតិមួយចំនួន នៅតែឃើញមាននៅតំបន់ដីសើមនៃប្រទេសកម្ពុជា (Colin et al., 2003)។ ក្នុងបញ្ជីក្រហមនៃអង្គការ IUCN បានបែងចែកចំណាត់ថ្នាក់នៃការគំរាមកំហែងប្រភេទសត្វចំនួន ៤

ប្រភេទដូចជា៖ ប្រភេទជិតផុតពូជខ្លាំង ប្រភេទជិតផុតពូជ ប្រភេទងាយរងគ្រោះថ្នាក់ និងប្រភេទជិតទទួលរងការគំរាមកំហែង ឬមិនមានទិន្នន័យគ្រប់គ្រាន់។ ក្នុងនោះដែរ សត្វស្លាបចំនួន៣៦ប្រភេទ ត្រូវបានចុះក្នុងបញ្ជីក្រហមនេះ។ ចំណែកឯរបាយការណ៍របស់អង្គការសត្វស្លាបអន្តរជាតិវិញ បានកត់ត្រាប្រភេទសត្វស្លាប ដែលកំពុងរងការគំរាមកំហែងជាលក្ខណៈអន្តរជាតិ និង ជិតរងការគំរាមកំហែង ៤៤ប្រភេទ (Hout et al., 2003)។ ប្រភេទសត្វស្លាប «Greater Flamingo» និង «Indian Skimmer» អាចផុតពូជពីក្នុងប្រទេសកម្ពុជាកាលពីប៉ុន្មានឆ្នាំនាពេលថ្មីៗនេះរួចហើយ (Colin et al., 2003)។

តាមការសិក្សាអង្កេតមួយចំនួននៅភូមិភាគឥសាន្ត បានរកឃើញសត្វត្រយងយក្ស ត្រយងចង្កំកស ពពូលទឹក និងសត្វក្រៀលបង្កាត់ពូជ ហើយក៏ឃើញមានសត្វក្រៀលនៅខេត្តតាកែវ និងកំពត ដែលផ្លាស់ទីទៅកាន់តំបន់ដីសើម ទំនាបលិចទឹក នៅបឹងទន្លេសាបជាប់ខេត្តសៀមរាប និង បន្ទាយមានជ័យ នៅទិសពាយ័ព្យប្រទេសកម្ពុជាផងដែរ (Colin et al., 2003)។

### *គ.ប្រភេទត្រី*

នៅប្រទេសកម្ពុជា គេបានប៉ាន់ប្រមាណថា ចំនួនប្រភេទត្រីទឹកសាបមានប្រមាណ៨៥០ទៅ ១២០០ប្រភេទ។បើតាមកំណត់

បង្ហាញរបស់គេហទំព័រ Fishbase[5] បានប៉ាន់ប្រមាណចំនួនប្រភេទត្រីទឹកសាបក្នុងប្រទេសកម្ពុជាត្រឹម ៤៨៦ប្រភេទ និងត្រីទឹកសមុទ្រ/ទឹកភ្លាវត្រឹម ៣៥៧ប្រភេទ សរុបនៅក្នុងប្រទេសកម្ពុជាមានចំនួន ៨៤៣ប្រភេទ។

## ឃ. ប្រភេទឧរង្គសត្វល្មូននិងថលជលិកសត្វ

ឧរង្គសត្វរួមមានក្រុមសត្វ ដែលគេស្គាល់ច្បាស់មានដូចជា៖ សត្វអណ្តើក ក្រពើ ពស់ ត្រកួត និងពួកថលជលិក (កង្កែប គីង្គក់) និងពួកសត្វមានទម្រង់ដូចជាជង្កូវ ដែលគេមិនសូវស្គាល់ដូចជា៖ ពួក Order Caecilians ។ល។ មកដល់ពេលនេះមិនទាន់មានការប៉ាន់ស្មានទៅលើចំនួន និងស្ថានភាពអេកូឡូស៊ីរបស់សត្វប្រភេទនេះនៅឡើយទេ លើកលែងពូជសត្វអណ្តើក។ ការសិក្សាមួយចំនួនរបស់អង្គការ WCS និង FFI បានធ្វើការប្រមូលផ្តុំសំណាកជាច្រើន ហើយបន្ទាប់ពីបញ្ចប់ការវិភាគរួចមក គេអាចនឹងពង្រីងចំណេះដឹង អំពីវត្តមាន និង របាយសត្វផ្សេងៗនៅក្នុងប្រទេសកម្ពុជា (Smith, 2001)។ ប្រភេទឧរង្គសត្វចំនួន ១៥ ប្រភេទក្នុងប្រទេសកម្ពុជា ត្រូវបានចុះក្នុងបញ្ជីក្រហមនៃអង្គការ IUCN។

---

[5] មើលគេហទំព័រ www.fishbase.org

### ង. ប្រភេទរុក្ខជាតិ

ប្រភេទរុក្ខជាតិនៅប្រទេសកម្ពុជា ដែលគេស្គាល់មានចំនួនប្រមាណជា ២ ៣០៨ប្រភេទ តែការវាយតម្លៃនេះមិនទាន់ត្រឹមត្រូវនៅឡើយទេ ព្រោះតួលេខនេះមានចំនួនតិចណាស់ បើប្រៀបទៅនឹងបញ្ជីសារពើភ័ណ្ឌរួមនៃប្រភេទរុក្ខជាតិ ដែលបានកត់ត្រានៅប្រទេសឡាវ កម្ពុជា វៀតណាម ដែលមានប្រមាណពី ១២ ០០០-១៥ ០០០ ប្រភេទ (Smith 2001)។ Phon (2000) បានឱ្យដឹងថាក្នុងចំណោមរុក្ខជាតិសំខាន់ៗចំនួន ១ ២៥៤ប្រភេទ នៅប្រទេសកម្ពុជាមានរុក្ខជាតិ ២៩ប្រភេទ ដុះនៅតាមតំបន់មួយចំនួនប៉ុណ្ណោះ។ មកទល់នឹងឆ្នាំ២០០២ រុក្ខជាតិចំនួន ៣៨ ប្រភេទ ត្រូវចុះក្នុងបញ្ជីក្រហមនៃអង្គការ IUCN។

## ៣. ស្ថានភាពជីវៈចម្រុះនៅខេត្តកោះកុង

**ភាពរេចរិលនៃធនធានជីវៈចម្រុះ៖** ជាបញ្ហាចម្បងបំផុតចំពោះមុខសម្រាប់តំបន់ការពារធម្មជាតិសមុទ្រ និងតំបន់ឆ្នេរនៃប្រទេសកម្ពុជា។ តាមរយៈការសិក្សានយោបាយព្រៃឈើឆ្នាំ ១៩៩៧ និង១៩៩៨ របស់ធនាគារពិភពលោក បានបង្ហាញថា អត្រានៃការកាប់ព្រៃអាចនឹងធ្វើឱ្យបាត់បង់ធនធានព្រៃឈើជាច្រើនប្រភេទដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់។ តាំងពីពេលនោះមក រាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្ដីប្រកាសផ្អួច

ផ្ដើមកាត់បន្ថយអត្រាកាប់ព្រៃឈើ ប៉ុន្តែគេនៅពុំទាន់ច្បាស់នៅឡើយថា វិធានការណ៍នោះបានទទួលជោគជ័យ ឬយ៉ាងណានោះឡើយ។ ភាពរេចរិលនៃជីវៈចម្រុះក៏កើតឡើង តាមរយៈការធ្វើជំនួញសត្វព្រៃ និងផលិតផលបានពីសត្វព្រៃ ដែលជាមូលហេតុបន្តឱ្យមានការបាត់បង់ប្រភេទមួយចំនួននិងបន្ថែមការលំបាកដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ មូលហេតុនៃការបន្តភាពរេចរិលជីវៈចម្រុះគឺវត្តមាននៃឧបសគ្គ ដែលមិនអាចឱ្យប្រព័ន្ធតំបន់ការពារធម្មជាតិសមុទ្រ និងតំបន់ឆ្នេរមានប្រសិទ្ធភាព។

ទោះបីប្រជាជនក្នុងភូមិយល់ឃើញថា ការបំផ្លាញជម្រកព្រៃជាបញ្ហាធ្ងន់ធ្ងរ តែការកាប់បំផ្លាញព្រៃសម្រាប់លក់នៅតែមានច្រើន។ ទាំងនេះធ្វើឱ្យមានការព្រួយបារម្ភណ៍ចំពោះការបាត់បង់ជម្រកក្នុងដែនសមុទ្រ ដូចជា ស្មៅសមុទ្រ ព្រៃកោងកាង និងការបាត់បង់ធនធានសមុទ្រ។

ផលនេសាទសមុទ្រ ជាប្រភពធនធានដ៏មានសារៈសំខាន់សម្រាប់បម្រើសេចក្ដីត្រូវការរបស់មនុស្ស និងសត្វ។ ក្តាម ខ្យង បង្គា មឹក និងត្រីសមុទ្រគ្រប់ប្រភេទ ជាអាហារដ៏ពេញនិយមសម្រាប់ភ្ញៀវទេសចរណ៍។ ប៉ុន្តែបើតម្រូវការទីផ្សារអាហារសមុទ្រនៃភ្ញៀវទេសចរណ៍កើនឡើង បរិមាណនៃការ

ផ្តត់ផ្គង់ធនធាន នឹងកើនឡើងដែលជាហេតុធ្វើឱ្យធនធានទាំងនេះងាយនឹងវិនាស។

សកម្មភាពនេសាទខុសច្បាប់ជាច្រើន បានបំផ្លិចបំផ្លាញមច្ឆជាតិក្នុងដែនសមុទ្រយ៉ាងគំហុក ដោយប្រើមងក្រឡាញឹកអូសជាប់ទាំងមច្ឆជាតិតូចធំ។ សកម្មភាពទាំងនេះបានបំផ្លាញដល់អេកូឡូស៊ីធម្មជាតិ ដោយសារតែមងក្រឡាញឹកតូចៗនៃទូកឱុនអូសដោយជាប់ទាំងពងនិងកូនក្តាម បង្គា និង ខ្យងតូចៗ។ ទូកឱុនអូសបង្គា ត្រី មានចំនួនលើសពី១០០គ្រឿង និងនៅមានទូកអូសកូនគ្រែងធំ និងតូច និងប្រភេទទូកនេសាទជាច្រើនគ្រឿងផ្សេងទៀតកំពុងចរាចរ និងបង្កការប៉ះពាល់ដល់ពួកមច្ឆជាតិ និងប្រភពចំណីអាហាររបស់មច្ឆជាតិនានា។

## ៤. ប្រភេទជីវៈចម្រុះ និងការអភិរក្សនៅខេត្ត កោះកុង

ដែនជម្រកសត្វព្រៃពាមក្រសោប កំពុងប្រឈមមុខនឹងការគម្រាមកំហែង ដោយសារតែផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដូចជា៖ កំណើនឡើងព្យុះសមុទ្រតាមតំបន់ឆ្នេរកាន់តែខ្លាំង អត្រាភ្លៀងធ្លាក់មិនទៀងទាត់ កំណើនសីតុណ្ហភាពទឹក ការហូរចូលទឹកប្រៃ ភាពរាំងស្ងួត និងទឹក

ជំនន់ជាដើម[6]។ បញ្ហាដែលរៀបរាប់មកនេះ បានបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ប្រភេទជីវចម្រុះ ដែលកំពុងមាន និងរស់នៅក្នុងតំបន់ឆ្នេររបស់ប្រទេសកម្ពុជា ក៏ដូចជាតំបន់ឆ្នេរនៅសហគមន៍ពាមក្រសោបនៃខេត្តកោះកុង។

ខាងក្រោមនេះ ជាព័ត៌មានពីប្រភេទជីវៈចម្រុះនិងសកម្មភាពនៃការអភិរក្សជីវៈចម្រុះដែលមាននៅក្នុងសហគមន៍ដែនជម្រកសត្វព្រៃពាមក្រសោបនៃខេត្តកោះកុង។ ក្នុងនោះដែរសកម្មភាព ដែលស្ថាប័នរដ្ឋាភិបាល និង បណ្តាអង្គការជាតិ និងអន្តរជាតិ កំពុងយកចិត្តទុកដាក់ថែរក្សា និងការពារធនធានធម្មជាតិ ក្រោមកិច្ចសហការជាមួយអាជ្ញាធរដែនដី ក៏នឹងត្រូវលើកមកបង្ហាញជាបន្តបន្ទាប់។

## ៤.១. ប្រភេទជីវៈចម្រុះ

បើតាមការស្រាវជ្រាវកន្លងមក ក្រសួងបរិស្ថាន អង្គការ IUCN[7] និងស្ថាប័នពាក់ព័ន្ធបរិស្ថាន បានបង្ហាញឱ្យដឹងអំពីភាព

---

[6] អត្ថបទស្រាវជ្រាវរបស់ក្រសួងបរិស្ថាន៖ "Climate Change and Food Insecurity: Understanding Coastal Community Resilience in Peam Krasaop Wildlife Sanctuary, Koh Kong Cambodia"។

[7] International Union for Conservation of Nature (IUCN)

សម្បូរបែបនៃប្រភេទជីវៈចម្រុះ ដែលមាននៅខេត្តកោះកុង ជាពិសេសនៅដែនជម្រកសត្វព្រៃពាមក្រសោម។ ប្រភពធនធានទាំងនោះ ត្រូវរួមបញ្ចូលទាំងប្រភេទព្រៃឈើនិងរុក្ខជាតិសមុទ្រ បក្សី ថនិកសត្វ សត្វល្មូន និងមច្ឆជាតិជាច្រើន។ ការស្រាវជ្រាវរបស់ An et al. (2009) បានគូសបញ្ជាក់យ៉ាងច្បាស់អំពីចំនួនប្រភេទសត្វព្រៃ ដែលមានក្នុងសហគមន៍នៅតំបន់ដែនជម្រកសត្វព្រៃពាមក្រសោប សរុបមានចំនួន ៦១ប្រភេទ[៨]។ ក្នុងនោះដែរ ពួកថនិកសត្វមានចំនួន ២៤ប្រភេទ ពួកបក្សីមានចំនួន ២៧ប្រភេទ និង ពួកសត្វល្មូនមានចំនួន១០ប្រភេទ (ឧបសម្ព័ន្ធទី១)។ តែទោះជាយ៉ាងណាក៏ដោយ ប្រភេទសត្វសំខាន់ៗមួយចំនួន ទំនងជានៅមានវត្តមាន ហើយប្រភេទសត្វមួយចំនួនទៀតក៏កម្រនឹងបានឃើញ ឬកំពុងស្ថិតក្នុងការគំរាមកំហែងដែលអាចនឹងឈានដល់ការផុតពូជ ឬក៏ទំនងជានៅសល់ត្រឹមឈ្មោះ។ ក្នុងឧបសម្ព័ន្ធទី១ ក៏មានបង្ហាញអំពីរូបភាពរបស់ពួកថនិកសត្វ បក្សី និងសត្វល្មូន ដែលជាការ

[៨] ក្នុងកំណត់បង្ហាញឯកសារដើម ចំនួនសត្វដែលរៀបរាប់មានចំនួនសរុប ៦៣ ក៏ប៉ុន្តែក្នុងនោះមានប្រភេទសត្វចំនួន២ប្រភេទដូចគ្នាក្នុងអំបូរបក្សីនិងសត្វល្មូនត្រូវបានដាក់បង្ហាញដោយសារតែវត្តមានរបស់សត្វទាំងពីរប្រភេទនោះ ត្រូវរកឃើញមានរស់នៅក្នុងតំបន់ពីរផ្សេងគ្នា។

ស្រាវជ្រាវសម្រាប់ជាព័ត៌មានបន្ថែមពីប្រភេទសត្វមួយចំនួនដែលបានរកឃើញនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប។ ក្រៅពីនេះ ព្រៃកោងកាង និងអត្ថប្រយោជន៍សម្រាប់ប្រភេទជីវៈចម្រុះ កត្តាគំរាមកំហែង និងបញ្ហាទាក់ទងនឹងប្រភេទព្រៃកោងកាង នឹងត្រូវលើកយកមកពិភាក្សា។

## *ប្រភេទព្រៃឈើក្នុងដែនជម្រកសត្វព្រៃពាមក្រសោប*

នៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប មានប្រភេទព្រៃជាច្រើនប្រភេទ ផ្ដល់ជាជម្រកដល់ជីវៈចម្រុះក្នុងព្រៃការពារនេះ ដែលគេស្គាល់នៅតំបន់ដែនជម្រកសត្វព្រៃពាមក្រសោបនៃខេត្តកោះកុង មានដូចជា៖ ព្រៃកោងកាង ព្រៃស្រោង ព្រៃស្មាច់ ព្រៃស្មែរ ព្រៃប្រសាក់ ព្រៃស្វាវ ព្រៃក្រញឹប ព្រៃឫស្សី និងព្រៃក្បាញ (ឧបសម្ព័ន្ធទី២)។ ព្រៃទាំងនេះ មានតួនាទីសំខាន់ណាស់សម្រាប់ជាជម្រកដល់ជីវៈចម្រុះជាច្រើនប្រភេទ ហើយប្រភេទព្រៃជម្រកដែលសំខាន់សម្រាប់ជីវៈចម្រុះស្នាក់អាស្រ័យច្រើនជាងគេក្នុងដែនជម្រកសត្វព្រៃពាមក្រសោបនេះគឺប្រភេទព្រៃកោងកាង។



រូបភាពទី៦៖ ព្រៃកោងកាងនៅតំបន់ឃុំពាមក្រសោប
ថតថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥



រូបភាពទី៧៖ ជីវៈចម្រុះនៅក្នុងតំបន់ព្រៃកោងកាង ឃុំពាមក្រសោប
ថតថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥

បើតាមប្រភពរបាយការណ៍របស់ក្រសួងបរិស្ថាន[១] ចុះផ្សាយឆ្នាំ ២០០៧ បានបញ្ជាក់ថាតំបន់ឆ្នេរដែលមានព្រៃគ្របដណ្តប់ក្រាស់ជាងគេ គឺមាននៅខេត្តកោះកុង (៨៣% ឬជាង ១លានហត) និងបន្ទមកគឺនៅខេត្តព្រះសីហនុ (៥៤% ឬ ៨១ ៥៣៩ ហត)និងខេត្តកំពត(៤៨% ឬ ២២៤ ៧៣០ ហត)។ ព្រៃឈើប្រមាណជា ៧០%ទៅ៨០% នៅខេត្តកោះកុង គឺជាប្រភេទព្រៃកោងកាង ព្រៃឫស្សី ព្រៃល្បាស់ រុក្ខជាតិបៃតងតូចៗ។ ព្រៃកោងកាងតាមតំបន់ឆ្នេរនៃប្រទេសកម្ពុជា ដែលគេបានស្គាល់ មានសរុបចំនួន ៤១ប្រភេទ (ឧបសម្ព័ន្ធ ទី៤)។ តែក៏មិនមានប្រភពព័ត៌មានពីវិសាលភាពនៃប្រភេទព្រៃឈើនីមួយៗទាំងនោះដែរ លើកលែងតែព្រៃកោងកាងដែលមានវិសាលភាពគ្របដណ្តប់លើផ្ទៃដីប្រមាណជា ៦៣ ៧០០ ហត (MoE, 2002)។

ប្រភេទព្រៃកោងកាងនេះ មានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាជម្រកនិងទម្រសម្រាប់រុក្ខជាតិទឹក និង ជីវៈចម្រុះជាច្រើនប្រភេទ ដែលរស់នៅតាមតំបន់មាត់សមុទ្រ ដូចជា៖ បក្សី

---

[១] របាយការណ៍អំពីស្ថានភាពបរិស្ថាននៅតំបន់ឆ្នេរនៃប្រទេសកម្ពុជា (ឆ្នាំ ២០០៧)។

សមុទ្រ ថនិកសត្វ សត្វល្មូន និងប្រភេទមច្ឆជាតិតូចជាច្រើន រួមមាន ត្រី ក្តាម បង្គារ បង្កង ជាដើម។ ក្រៅពីនេះ ព្រៃកោងកាង ក៏ផ្តល់ជាជម្រក និងប្រភពអាហារដល់ប្រភេទសត្វជាច្រើនផ្សេងទៀតដូចជា៖ សត្វបក្សី ឧរង្គសត្វ អណ្តើកសមុទ្រ និងប្រភេទសត្វក្នុងស្រុកជាច្រើនផ្សេងទៀត។

ព្រៃឈើ ជួយរក្សានូវប្រព័ន្ធអេកូឡូស៊ី និងតុល្យភាពតំបន់ឆ្នេរ។ ក្រៅពីនេះ ព្រៃកោងកាង ក៏ជួយជារបាំងខ្យល់ និងទប់ស្កាត់ការហូរច្រោះកាកសំណល់ កម្ទេចកំណ និងសារធាតុពុលចូលទៅក្នុងទឹកសមុទ្រផងដែរ។

តំបន់ព្រៃកោងកាង សម្បូរនៅតាមឆ្នេរនៃតំបន់ព្រៃការពារមួយចំនួនដូចជា៖ ឧទ្យានជាតិបទុមសាគរ ដែនជម្រកសត្វព្រៃពាមក្រសោប ដែនជម្រកសត្វព្រៃភ្នំសំកុស ហើយក៏មានដុះច្រើននៅតាមមាត់ឆ្នេរផងដែរ។ ព្រៃកោងកាងនៅដែនជម្រកសត្វព្រៃពាមក្រសោបក្នុងស្រុកមណ្ឌលសីម៉ា ជាតំបន់ដែលមានព្រៃកោងកាងដុះគ្របដណ្តប់ធំជាងគេបំផុត នៅក្នុងប្រទេសកម្ពុជា ហើយទំនងជាមានទំហំធំជាងគេនៅតាមតំបន់ឆ្នេរនៃឈូងសមុទ្រថៃ (MoE, 2002)។ តែបើតាមប្រភពព័ត៌មានពីនាយកខណ្ឌរដ្ឋបាលជលផលខេត្តកោះកុង នាពេលបច្ចុប្បន្ន

នេះ ស្រុកបទុមសាគរ ជាស្រុកដែលសម្បូរព្រៃកោងកាងច្រើនជាងគេ[10]។

បច្ចុប្បន្ន ព្រៃកោងកាងនៅខេត្តកោះកុង ស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្មនិងមន្ទីរបរិស្ថានខេត្តកោះកុង។ ដោយមានកិច្ចសហការជាមួយស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល មូលនីធិឃុំ និង សហគមន៍នេសាទ (តារាងទី១) ព្រៃកោងកាង បានទទួលការការពារនិងការដាំបន្ថែមនៅតាមតំបន់ឆ្នេរជាច្រើន ហើយក៏បានផ្តល់ជាប្រយោជន៍យ៉ាងសំខាន់ក្នុងការជួយរក្សា និងការពារដល់ប្រភពធនធានជីវៈចម្រុះបានជាច្រើនប្រភេទ។

ចំណែករុក្ខជាតិសមុទ្រមួយចំនួនទៀតដូចជា ស្មៅ សារ៉ាយសមុទ្រ និងផ្កាថ្មជាដើម ក៏ជាធនធានសំខាន់ផ្តល់ជាជម្រក ប្រភពចំណីដល់ហ្វូងមច្ឆជាតិផ្សេងៗ ប្រភពឱសថ និងប្រភពចំណូលដល់ប្រជាជនដែលរស់អាស្រ័យលើធនធានក្នុងសមុទ្រទាំងនោះដែរ។ ប៉ុន្តែព័ត៌មានអំពីប្រភេទរុក្ខជាតិសមុទ្រ

---

[10] បទសម្ភាសន៍ជាមួយនាយកខណ្ឌរដ្ឋបាលជលផលខេត្តកោះកុងលោក ក្បាង គិរី បង្ហាញថា ស្រុកបុទុមសាគរ ជាស្រុកមានព្រៃកោងកាងច្រើនជាងគេនាពេលបច្ចុប្បន្ននេះ។

និងមច្ឆជាតិសមុទ្រ នៅពុំទាន់មានការសិក្សាស្រាវជ្រាវឱ្យបានលំអិតច្បាស់លាស់នៅឡើយនោះទេ (An et al., 2009)។

តែទោះជាយ៉ាងណាក៏ដោយ នៅមិនទាន់មានការសិក្សាណាមួយឱ្យបានលម្អិតអំពីលក្ខណៈជីវសាស្ត្ររបស់ប្រភេទជីវៈចម្រុះ ដែលមាននៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោបនៅឡើយ។ ការសិក្សាកន្លងមកដែលបានបញ្ជាក់ខាងលើ បានបង្ហាញពីវត្តមាននៃប្រភេទជីវៈចម្រុះជាច្រើនប្រភេទ តែមិនបានបញ្ជាក់ពីប្រភេទ ដែលមានក្នុងខេត្តកោះកុងទាំងមូលនោះដែរ។ លទ្ធផលទាំងនោះ ជាករណីសិក្សាស្រាវជ្រាវក្នុងតំបន់ធំៗទាំង៥ ក្នុងដែនជម្រកសត្វព្រៃពាមក្រសោបដូចជា៖ នៅភូមិពាមក្រសោបពីរ ភូមិកោះស្រឡៅ ភូមិតាចាត ភូមិព្រែកស្វាយ និងភូមិកោះអណ្តែត។ ភូមិទាំងនេះ សុទ្ធជាភូមិដែលមានប្រជាជនរស់នៅច្រើនជាងគេក្នុងឃុំទាំង៦ នៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោបគិតមកត្រឹមឆ្នាំ ២០០៩។

## ៤.២. ការអភិរក្សជីវៈចម្រុះ

### *៤.២.១. ការរៀបចំកំណត់តំបន់អភិរក្ស*

ការអភិរក្សប្រភេទជីវៈចម្រុះ នៅតំបន់សហគមន៍ដែនជម្រកសត្វព្រៃពាមក្រសោប មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងការអភិរក្សតំបន់ព្រៃកោងកាង ដែលជាទីជម្រក និងផ្តល់ជា

ប្រកពចំណីយ៉ាងសំខាន់សម្រាប់ការរស់នៅ និងលូតលាស់របស់ជីវៈចម្រុះគ្រប់ប្រភេទនៅតំបន់ឆ្នេរភាគនិរតីមួយនេះ។

ការអភិរក្សតំបន់ព្រៃកោងកាង បានក្លាយជាចំណុចសំខាន់ សម្រាប់ជួយដល់កិច្ចប្រឹងប្រែងក្នុងការអភិរក្សប្រភេទជីវៈចម្រុះផ្សេងៗ ដែលមាននៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា។ តារាងទី១ បានបង្ហាញយ៉ាងច្បាស់ អំពីការប្រឹងប្រែងរក្សាការពារនិងដាំបន្ថែមកូនព្រៃកោងកាងនៅខេត្តកោះកុង។ សហគមន៍នៃដែនជម្រកសត្វព្រៃពាមក្រសោប ដែលគ្របដណ្តប់លើតំបន់ពីរផ្សេងគ្នាគឺ ឃុំពាមក្រសោប (ស្រុកមណ្ឌលសីមា) និងឃុំកោះកាពិ (ស្រុកកោះកុង) និងបានក្លាយជាតំបន់មានសក្តានុពលទទួលបានការយកចិត្តទុកដាក់ពីសំណាក់រដ្ឋបាលជលផល មូលនីធិឃុំ អង្គការក្រៅរដ្ឋាភិបាលអង្គការធ្វើការផ្នែកបរិស្ថាននានា សហគមន៍នេសាទ និងក្រុមយុវជនស្ម័គ្រចិត្តក្នុងការបន្តនិងពង្រីកការដាំកូនកោងកាង។ តំបន់នេះ ក៏ត្រូវបានបង្កើតជាតំបន់សហគមន៍ទេសចរណ៍ធម្មជាតិ និងនេសាទ និងជាទីតាំងនៃការអភិរក្សប្រភេទជីវៈចម្រុះយ៉ាងសំខាន់នៅក្នុងខេត្តកោះកុង។

ក្រៅពីនេះ តំបន់ព្រៃកោងកាងជាធនធានមាត់សមុទ្រ ដែលបានផ្តល់អត្ថប្រយោជន៍យ៉ាងសំខាន់ ដល់ការរស់រាននៃប្រភេទជីវចម្រុះជាច្រើនប្រភេទនៅតំបន់ឆ្នេរ។ វាមានតួនាទី

យ៉ាងសំខាន់ក្នុងការផ្តល់ជាជម្រក ទម្រសម្រាប់រុក្ខជាតិទឹកនិង ជីវៈចម្រុះជាច្រើនប្រភេទ រក្សានូវប្រព័ន្ធអេកូឡូស៊ី និង តុល្យភាពតំបន់ឆ្នេរ។ ព្រៃកោងកាង ក៏ជួយជារបាំងខ្យល់ និង ទប់ស្កាត់ការហូរច្រោះកាកសំណល់ កម្អេចកំណ និង សារ ជាតុពុលចូលទៅក្នុងទឹកសមុទ្រផងដែរ។ ប៉ុន្តែតំបន់ព្រៃជម្រក សត្វទាំងនេះ កំពុងរងការខូចខាតនិងកំពុងប្រឈមមុខនឹងការ សឹករេចរិល និងអាចឈានដល់ស្ថានភាពហិនហោចបើគ្មាន វិធានការណ៍ការពារនិងទប់ស្កាត់។ ហេតុនេះ ប្រភពជីវៈចម្រុះ ដែលរស់នៅតាមតំបន់ឆ្នេរសមុទ្រ នឹងទទួលរងឥទ្ធិពលជា អវិជ្ជមានប៉ះពាល់ដល់ការលូតលាស់ និងងាប់ជាបន្តបន្ទាប់។

ហេតុដូច្នេះហើយ ការកំណត់ឱ្យច្បាស់អំពីតំបន់អភិរក្ស ក្នុងដែនជម្រកសត្វព្រៃពាមក្រសោបនេះ ជាវិធានការណ៍ដ៏ សំខាន់ដែលត្រូវយកចិត្តទុកដាក់។ តំបន់អភិរក្សព្រៃជម្រក សត្វ ផ្តល់អត្ថប្រយោជន៍ដល់ការរស់រានរបស់ប្រភេទជីវៈចម្រុះ គ្រប់ប្រភេទ ហើយក៏ជួយគាំទ្រដល់សកម្មភាពអភិរក្សដែរ។

ដោយមានកិច្ចសហការរវាងក្រសួងបរិស្ថាន និងស្ថាប័ន ពាក់ព័ន្ធនានា តំបន់គ្រប់គ្រងចំនួនបួនត្រូវបានកំណត់ឡើង ក្នុងដែនជម្រកសត្វព្រៃពាមក្រសោប សម្រាប់ជួយដល់ការអភិ រក្សប្រភេទសត្វដែលកំពុងរងគ្រោះ ការពារព្រៃជម្រកសត្វ និង កំណត់ពីទីប្រជុំជន (MoE, 2009)។ តារាងទី២ បង្ហាញយ៉ាង

ច្បាស់ពីវិសាលភាពនៃតំបន់គ្រប់គ្រងទាំងបួន ក្នុងដែនជម្រកសត្វព្រៃពាមក្រសោបខេត្តកោះកុង គឺ៖ (១) តំបន់ស្នូល (២) តំបន់អភិរក្ស (៣) តំបន់សហគមន៍ និង (៤) តំបន់ប្រើប្រាស់ដោយចីរភាព។

នៅឆ្នាំ ២០១១ ផែនទីកំណត់បែងចែកតំបន់គ្រប់គ្រងទាំងបួនក្នុងដែនជម្រកសត្វព្រៃពាមក្រសោបខេត្តកោះកុង ត្រូវបានកំណត់ឡើងយ៉ាងច្បាស់លាស់លើផ្ទៃដីសរុបចំនួន ២៥ ៨៩៧ហ.ត. ស្ថិតក្នុងដែនដីរដ្ឋបាលស្រុកស្មាច់មានជ័យ (បច្ចុប្បន្នជាក្រុងខេមរភូមិន្ទ) និងស្រុកមណ្ឌលសីម៉ា ស្របតាមមាត្រាទី១១ នៃច្បាប់ស្តីពីតំបន់ការពារ បំណងជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃពាមក្រសោប។ តំបន់គ្រប់គ្រងនីមួយៗ មានលក្ខណៈពិសេសនៃការគ្រប់គ្រងដោយឡែកពីគ្នា (ឧបសម្ព័ន្ធទី៣) ហើយការបែងចែកនេះ ជាចំណុចសំខាន់ សម្រាប់កំណត់ព្រំដែនក្នុងតំបន់ព្រៃការពារក្នុងដែនជម្រកសត្វព្រៃពាមក្រសោប។

តារាង ១៖ ទិន្នន័យនិងទីតាំងដាំព្រៃកោងកាងនៅខេត្តកោះកុង

| ឈ្មោះទីតាំង | | | ទីតាំងដាំចាស់ | | ទីតាំងដាំថ្មី | ឧបត្ថម្ភដោយ |
|---|---|---|---|---|---|---|
| ស្រុក | ឃុំ | ភូមិ | ដាំថ្មី | ដាំជួស | ចំនួនដើម | |
| ស្រែអំបិល | ជីខក្រោម | អន់ឆ្នើត | ២២ ២៣០ | - | ៣០ ០០០ | ជលផល អង្គការFAO |
| | | តាបែន | - | ៣០ ០០០ | ៣០ ០០០ | មូលនិធិឃុំជីខក្រោម |
| | | ចំបក់ | - | ១០០ ០០០ | ៥០ ០០០ | អង្គការសង្គ្រោះសត្វព្រៃ |
| | ជ្រោយស្វាយ | ជ្រោយស្វាយ | - | ៤៦ ០០០ | ១១០ ០០០ | អង្គការម្លប់ព្រហ្មវិហារធម៌ |
| បុទុមសាគរ | កណ្តាល | កណ្តាល | - | ៣ ០០០ | ៧០ ០០០ | DANIDA |
| | អណ្តូងទឹក | តាមាឃ | ៤៧ ០០០ | - | ១០០ ០០០ | ជលផល យុវជនស្ម័គ្រចិត្ត |
| | | ប្រែ | - | ៧០ ០០០ | - | មូលនិធិ ADB |
| | ថ្មស | ស្រែត្រាវ | - | ៥៣ ០០០ | ៤០ ០០០ | ជលផល សហគមន៍នេសាទ |
| | | ស្រែថ្មី | - | ៨៦ ៧០០ | ៤០ ០០០ | ជលផល គ.ជ.អ.ប |
| មណ្ឌលសីមា | ពាមក្រសោប | | - | ២ ៨២០ ០០០ | ១០០ ០០០ | ជលផល មូលនិធិឃុំ NGOs |
| កោះកុង | កោះកាពិ | | - | ៩៤០ ០០០ | ១៥០ ០០០ | ជលផល មូលនិធិ ADB NGOs |
| សរុប | | | ៦៩ ២៣០ | ៤ ១៤៨ ៧០០ | ៧២០ ០០០ | |

(ប្រភព៖ មន្ទីរបរិស្ថានខេត្តកោះកុង ឆ្នាំ ២០១៣)

តារាង ២៖ ការកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃពាមក្រសោប ខេត្តកោះកុង

| ល.រ | តំបន់គ្រប់គ្រងទាំងបួន | ទំហំ |
|---|---|---|
| ១ | តំបន់ស្នូល ( Core zone ) | ១ ៥៨៨ ហត |
| ២ | តំបន់អភិរក្ស (Conservation zone) | ៤ ៨៧៣ ហត |
| ៣ | តំបន់សហគមន៍ (Community zone) | ៤ ០២៣ ហត |
| ៤ | តំបន់ប្រើប្រាស់ដោយចីរភាព (Sustainable use zone) | ១៥ ៤១៣ ហត |

### *៤.២.២. យុទ្ធសាស្ត្រនៃការអភិរក្សជីវៈចម្រុះ*

ដោយមានកិច្ចសហការ និងគាំទ្រពីមន្ទីរបរិស្ថានខេត្ត រដ្ឋបាលជលផល មូលនីធិឃុំ និង ការឧបត្ថម្ភពីអង្គការជាតិ និងអន្តរជាតិនានា សហគមន៍ដែនជម្រកសត្វព្រៃពាមក្រសោប បានរៀបចំកំណត់យ៉ាងច្បាស់ពីតំបន់សំខាន់ៗ តាមអនុក្រិត ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ (តារាងទី២)។ តំបន់ស្នូល និងតំបន់អភិរក្ស ត្រូវកំណត់ជាតំបន់សំខាន់ជាងគេក្នុងការ រក្សាការពារប្រេកពព្រៃកោងកាងនានា សម្រាប់ជាប្រយោជន៍ ដល់ការលូតលាស់ និងការរស់នៅរបស់ជីវៈចម្រុះនៅតំបន់ សហគមន៍នេះ។ ការអភិរក្សទាំងនេះ បានចូលរួមចំណែកក្នុង ការថែរក្សានូវបរិមាណព្រៃកោងកាង នៅតំបន់សហគមន៍នៃ

ដែនជម្រកសត្វព្រៃពាមក្រសោប ក្រោមសកម្មភាពការអភិរក្សតាមគោលការណ៍ធម្មជាតិ។

ក្រៅអំពីនេះ ការអភិរក្សប្រភពជីវៈចម្រុះ មានការរៀបចំអនុវត្តន៍ដោយម៉ត់ចត់ ក្រោមរូបភាពនៃការគ្រប់គ្រងរួមគ្នា ការបន្តដាំស្តារឡើងវិញ និងការចូលរួមពីប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ពាមក្រសោប។ ការគ្រប់គ្រងរួមគ្នានេះ ជាការគ្រប់គ្រងដោយផ្ទាល់ពីស្ថាប័នរដ្ឋ ក៏ដូចជាមានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធនានាផងដែរ។ នៅទសវត្សឆ្នាំ១៩៨០ ព្រៃកោងកាងបានទទួលរងការកាប់បំផ្លាញ ធ្វើជាអុសធ្យូងយ៉ាងខ្លាំងគួរឱ្យព្រួយបារម្ភ ហើយក៏ជាមូលហេតុមួយបង្កការប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជនក្នុងតំបន់យ៉ាងធ្ងន់ធ្ងរ។ ការអំពាវនាវពីស្ថាប័នរដ្ឋនិងស្ថាប័នពាក់ព័ន្ធ ដល់ប្រជាពលរដ្ឋក្នុងតំបន់ឱ្យយល់ពីផលប្រយោជន៍របស់ព្រៃកោងកាងចំពោះជីវភាពរស់នៅ ជាពិសេសការផ្តល់នូវព័ត៌មានទាក់ទងនឹងការបំផ្លាញប្រភពធនធានព្រៃកោងកាង បានក្លាយជាមធ្យោបាយដ៏មានប្រសិទ្ធភាព។

ស្នាក់ការដែនជម្រកសត្វព្រៃពាមក្រសោប ដែលស្ថិតនៅក្នុងសហគមន៍ពាមក្រសោបនៅឆ្នាំ២០១៤ ភូមិបាងកាយ៉ាក់ ឃុំពាមក្រសោប បានរៀបចំរោងបណ្តុះកូនកោងកាងនៅក្នុងទីធ្លាទីស្នាក់ការ។ រោងបណ្តុះកូនកោងកាងនេះ ត្រូវរៀបចំដាំនៅ

រាល់ខែមិថុនារៀងរាល់ឆ្នាំ សម្រាប់ផ្គត់ផ្គង់ដល់គ្រប់តម្រូវការនៃការដាំកូនកោងកាងក្នុងដែនជម្រក។ បើតាមការបង្ហាញពីមន្ត្រីបម្រើការនៅដែនជម្រកសត្វព្រៃពាមក្រសោបនេះ បានបញ្ជាក់ថា មានគម្រោងពីស្ថាប័នរដ្ឋ និងអង្គការជាច្រើន ចូលរួមក្នុងការដាំកូនកោងកាងថ្មីនៅក្នុងគោលដៅផ្សេងគ្នាជាច្រើននៅតាមតំបន់ឆ្នេរនៃខេត្តកោះកុង (តារាងទី១)។

## ៤.៣. បញ្ហាប្រឈមក្នុងដែនជម្រកសត្វព្រៃ

បើតាមប្រភពព័ត៌មានពីមន្ទីរបរិស្ថាននៃខេត្តកោះកុង បានឱ្យដឹងថា តំបន់ព្រៃកោងកាងតាមមាត់សមុទ្រនៃតំបន់ឆ្នេរនៅក្នុងខេត្តកោះកុង កំពុងរងការប៉ះពាល់ដោយសារកត្តាពីរសំខាន់ គឺៈ កត្តាមនុស្ស និង កត្តាអាកាសធាតុ។ ការកាប់ព្រៃកោងកាងធ្វើធ្យូង ជាមូលហេតុចម្បងនាំដល់ការវិនាសតំបន់ព្រៃកោងកាងនៅខេត្តកោះកុងកន្លងមក (An et al., 2009) ហើយការពង្រីកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក៏បានចូលរួមចំណែកក្នុងការបំផ្លាញតំបន់ព្រៃកោងកាងនៅតាមតំបន់ឆ្នេរនៃប្រទេសកម្ពុជា (Nordeco and Baastel, 2012) ។ ទាំងនេះ បានបញ្ជាក់យ៉ាងច្បាស់ពីសកម្មភាពរបស់មនុស្ស ដែលកំពុងធ្វើឱ្យវិនាសដល់ធនធានធម្មជាតិ មិនថាតែចំពោះតំបន់ព្រៃកោងកាងនោះទេ។



រូបភាពទី ៨៖ ទិដ្ឋភាពសឹករេចរឹលនៃព្រៃលិចទឹកតំបន់ឆ្នេរ

តាមកិច្ចសម្ភាសន៍ជាមួយអនុប្រធានមន្ទីរបរិស្ថានខេត្តកោះកុង លោក ហ៊ិន ម៉ារ៉ាឌី បានឱ្យដឹងថា មកទល់ពេលបច្ចុប្បន្ននេះ ការខូចខាតព្រៃកោងកាងដោយសារកត្តាមនុស្សមានការថយចុះច្រើន ប៉ុន្តែទោះជាយ៉ាងណា កត្តាអាកាសធាតុនៅតែជាកត្តាប្រឈមមុខ ដែលនាំឱ្យមានផលប៉ះពាល់ខ្លាំងដល់ព្រៃកោងកាងនៅតាមតំបន់ឆ្នេរខេត្តកោះកុង ជាពិសេសដោយសារបញ្ហាបម្រែបម្រួលអាកាសធាតុ។ បញ្ហានេះ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ឆ្នេរសមុទ្រកម្ពុជា។ ឆ្នេរខ្សាច់ត្រូវរងសំណឹករេចរិល ហើយក៏បន្តជះឥទ្ធិពលដល់ការលូតលាស់របស់ព្រៃកោងកាងបន្តិចម្តងៗ។ អ្វីដែលកាន់តែអាក្រក់ទៀតនោះគឺ ការសឹករេចរិលព្រៃកោងកាង បានធ្វើឱ្យប៉ះពាល់ដល់ប្រភពជីវៈចម្រុះដែលមានវត្តមាននៅទីនោះផងដែរ។

ការអភិរក្សប្រភេទជីវៈចម្រុះនៅតំបន់ឆ្នេរ ទាមទារឱ្យមាន កិច្ចសហការពីស្ថាប័នរដ្ឋាភិបាល ស្ថាប័ន-អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍នេសាទ ដើម្បីរួមចំណែកជួយរក្សាការពារប្រភពធនធានធម្មជាតិទាំងនោះ។ ក៏ប៉ុន្តែ ស្ថានភាពបច្ចុប្បន្ននេះ ការអភិរក្សជីវៈចម្រុះនៅខេត្តកោះកុង កំពុងតែប្រឈមមុខនឹងការលំបាកមួយចំនួនពាក់ព័ន្ធនឹងគោលការណ៍នៃការអភិវឌ្ឍនិងកិច្ចប្រឹងប្រែងក្នុងការរក្សា និងការពារតំបន់ដែលមានធនធានជីវៈចម្រុះ។ ការសិក្សាវាយតម្លៃអំពីផលប៉ះពាល់ផ្នែកបរិស្ថាន និងជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ឆ្នេរ ជាចំណុចចាប់ផ្តើមអំពីការអនុវត្តគម្រោងអភិវឌ្ឍន៍នានា។ ក៏ប៉ុន្តែ ការវាយតម្លៃអំពីផលប៉ះពាល់ផ្នែកបរិស្ថានដោយមានការចូលរួមពិភាក្សាយោបល់រវាងស្ថាប័នពាក់ព័ន្ធ និងប្រជាជនដែលរស់នៅក្នុងនិងជុំវិញតំបន់អភិវឌ្ឍន៍ ជាបញ្ហាចោទដែលថាតើដំណើរការនៃការវាយតម្លៃបានធ្វើឡើងដោយសមស្របឬយ៉ាងណា។ បញ្ហាផលប្រយោជន៍ កង្វះខាតការចុះត្រួតពិនិត្យ និង ធ្វើការសិក្សាឱ្យបានស៊ីជម្រៅជាក់ស្តែង ក៏ជាមូលហេតុដែលធ្វើឱ្យការអភិវឌ្ឍជះឥទ្ធិពលជាអវិជ្ជមាន ដល់ប្រភពធនធានធម្មជាតិ និងប្រភេទជីវៈចម្រុះ ដែលមានស្រាប់នៅក្នុងនិងជុំវិញបរិវេណនៃតំបន់អភិវឌ្ឍន៍។ ម្យ៉ាងវិញទៀត ភាពទន់ខ្សោយនៃការទំនាក់ទំនងរវាងស្ថាប័នពាក់ព័ន្ធ ដូចជា ផ្នែក

បរិស្ថាន កសិកម្ម ទេសចរណ៍ ឬក៏ផ្នែកជលផល ជាដើម ក៏អាចជាមូលហេតុនាំឱ្យរាំងស្ទះ ដល់កិច្ចសហការក្នុងការរក្សា និងការពារប្រភេទជីវៈចម្រុះនៅតាមតំបន់ឆ្នេរ ហើយក៏បន្តបង្កការប៉ះពាល់ដល់ប្រជាជន ដែលរស់នៅអាស្រ័យលើធនធានធម្មជាតិទាំងនោះផងដែរ។

តាមការសិក្សាស្រាវជ្រាវ និងផ្អែកលើបទសម្ភាសន៍ជាមួយមន្ត្រីរដ្ឋបាលជលផល និង ប្រជាកសិកររស់តាមតំបន់ឆ្នេរមួយចំនួន បានឱ្យដឹងថា សព្វថ្ងៃការវិនិយោគទុនមួយចំនួនបានកំពុងនឹងធ្វើឱ្យខូចខាតដល់ប្រព័ន្ធអេកូឡូស៊ីនិងតុល្យភាពតំបន់ឆ្នេរសមុទ្រនៅខេត្តកោះកុង។ ការកាប់បំផ្លាញព្រៃកោងកាងនិងរុក្ខជាតិនានាតាមបណ្តាស្រុកផ្សេងៗ (ដូចជានៅស្រុកបុទុមសាគរជាឧទាហរណ៍ស្រាប់) សម្រាប់ធ្វើការដាំដុះដំណាំឧស្សាហកម្មមួយចំនួន ក៏ដូចជាការបង្កើតជារីហ្សត (Resort) បានកំពុងធ្វើឱ្យខូចខាត ដល់ប្រភពធនធានជីវៈចម្រុះនៅខេត្តកោះកុងយ៉ាងគំហុក។ ទាំងនេះ បានបញ្ជាក់យ៉ាងច្បាស់អំពីចន្លោះប្រហោងនៃការគ្រប់គ្រងធនធានតំបន់ឆ្នេរពីស្ថាប័នពាក់ព័ន្ធ។

ស្ថានភាពខូចខាត និងការសឹករេចរិលនៃធនធានធម្មជាតិ នៅតំបន់សហគមន៍ដែនជម្រកសត្វព្រៃពាមក្រសោប ដែលបង្កដោយសកម្មភាពមនុស្ស និងដោយសារតែកត្តា

អាកាសធាតុ បានកំពុងតែបង្ហាញពីភាពខ្វះចន្លោះ។ ម្យ៉ាងទៀត លទ្ធភាពនៃការអភិរក្សប្រភពធនធានធម្មជាតិនៅតាមតំបន់ឆ្នេរ ក៏នៅមានកម្រិតតិចតួចនៅឡើយ។ ប្រសិនបើគ្មានវិធានការណ៍ទប់ស្កាត់ទាន់ពេលទល់នឹងសកម្មភាពខុសច្បាប់ដែលបង្កការប៉ះពាល់ដល់ជីវៈចម្រុះ ឬបើសិនគ្មានវិធានការណ៍ពង្រឹងផ្លូវច្បាប់ឱ្យមានប្រសិទ្ធភាពនោះទេ ធនធានធម្មជាតិក៏ដូចជាប្រភេទជីវៈចម្រុះនានា ត្រូវប្រឈមមុខនឹងការបាត់បង់ (MoE, 2002) ហើយប្រភេទជីវៈចម្រុះខ្លះ អាចនឹងឈានដល់ការផុតពូជ។ ស្ថានភាពទាំងនេះ នឹងបន្តជះឥទ្ធិពលដល់ការរស់នៅរបស់ប្រជាជនដែលរស់នៅពឹងផ្អែកលើធនធាននៅក្នុងទឹកសមុទ្រ។

MoE (2002) បានបញ្ជាក់យ៉ាងច្បាស់ថា ការអនុវត្តច្បាប់និងបទបញ្ញត្តិផ្សេងៗ មានសភាពធូររលុងនិងមិនបានកំណត់ឱ្យច្បាស់លាស់គ្រប់ជ្រុងជ្រោយនៅឡើយ ហើយទាំងនេះ ក៏ជាមូលហេតុនាំឱ្យមានសកម្មភាពជាច្រើនដែលបង្កការរំខាន និងបំផ្លិចបំផ្លាញប្រភេទជីវៈចម្រុះដែលមាននៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា។

តែទោះជាយ៉ាងណាក៏មានកិច្ចប្រឹងប្រែងពីស្ថាប័នរដ្ឋនិងឯកជនមួយចំនួន ដោយមានកិច្ចគាំពារពីអង្គការក្រៅរដ្ឋាភិបាល ដើម្បីថែរក្សា និងការពារធនធានធម្មជាតិនៅខេត្តកោះ

កុង។ ការបង្កើតតំបន់សហគមន៍ដែនជម្រកការពារសត្វព្រៃពាមក្រសោបជាតឹកតាងមួយ បញ្ជាក់ពីកិច្ចប្រឹងប្រែងអភិរក្សធនធានធម្មជាតិ ដែលមាននៅតំបន់ពាមក្រសោបនៃខេត្តកោះកុង។ ក្រៅពីនេះ សហគមន៍ដែនជម្រកសត្វព្រៃពាមក្រសោបបានអនុម័តនូវបទបញ្ជាផ្ទៃក្នុង សម្រាប់ការអនុវត្តនៅក្នុងសហគមន៍នេសាទ ក្នុងឃុំពាមក្រសោប (មើលរូបភាពទី៩)។



រូបភាពទី៩៖ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ឃុំពាមក្រសោប
ថតថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥

## ៥. ការរស់នៅនិងបញ្ហាប្រឈម

ប្រជាជននៅក្នុងឃុំពាមក្រសោមមានចំនួន ៣៣០ គ្រួសារ ស្មើនឹង ១ ៣៥៨នាក់ (គិតក្នុងឆ្នាំ២០១៤) ការរស់នៅរបស់គាត់ គឺពឹងផ្អែកទៅលើរបរនេសាទរហូតដល់៦៧%។ ចន្លោះឆ្នាំ១៩៩០ និង ១៩៩៣ ប្រជាជនប្រមាណជាចំនួន ៧៩គ្រួសារ ប្រកបរបរកាប់ព្រៃកោងកាងដើម្បីធ្វើធ្យូង រានព្រៃលិចទឹកធ្វើស្រែបង្គា ហើយសកម្មភាពទាំងនេះកាន់តែរីកដុះដាលខ្លាំងឡើងនៅក្នុងចន្លោះឆ្នាំ១៩៩៥ និង១៩៩៦។ ការបាត់បង់ព្រៃជាជម្រកពួកជីវៈចម្រុះ បានធ្វើឱ្យទឹកបានក្លាយទៅជាពណ៌ក្រហម ក្តាម បង្គា ត្រី ខ្យង និងប្រភេទសត្វដែលរស់នៅតាមព្រៃកោងកាងជាច្រើនប្រភេទមិនអាចអាស្រ័យ និងបន្តពូជបាន។ ស្ថានភាពទាំងនេះ បានបង្កការលំបាក និងប៉ះពាល់ជាខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាជន ដែលរស់នៅអាស្រ័យលើរបរនេសាទ។

ចំពោះប្រជាជនចំណូលស្រុកមកពីខាងក្រៅ ភាគច្រើនមកពីខេត្តកំពត កំពង់ចាម ព្រៃវែងជាដើម។ ពួកគេមកតាំងទីលំនៅនៅតំបន់នេះដោយប្រកបរបរនេសាទ ក្នុងនោះការប្រើឧបករណ៍នេសាទខុសច្បាប់ និងកំណើននៃការកាប់ព្រៃកោងកាងធ្វើធ្យូងកាន់តែច្រើន ជាកត្តាចំបងដែលបណ្តាលឱ្យប៉ះពាល់ដល់ធនធានជលផលនៅតំបន់ឆ្នេរ។ មូលហេតុចំបង

ដែលជំរុញឱ្យមានសកម្មភាពបំផ្លាញតំបន់ព្រៃកោងកាង និង ធនធនសមុទ្រទាំងនេះ គឺពាក់ព័ន្ធទៅលើកម្រិតនៃការយល់ដឹងរបស់ប្រជាជនម្ចាស់ស្រុក និងអ្នកចំណូលថ្មី។ ប្រជាជនមិនបានយល់ពីសារៈប្រយោជន៍ព្រៃកោងកាងដែលជាប្រភពចំណី និងជាទីជម្រកសម្រាប់ការរស់នៅរបស់សត្វគ្រប់ប្រភេទ ដូចជា ពួកបក្សី ថនិកសត្វ និង ពួកមច្ឆជាតិជាដើម។ អ្វីដែលសំខាន់នោះគឺ ព្រៃកោងកាង ជារបាំងការពារខ្យល់ របាំងបន្ថយឥទ្ធិពលរលក ក៏ដូចជារបាំងការពារដល់ប្រជាជនដែលរស់នៅតាមឆ្នេរសមុទ្រដែរ។

ម្យ៉ាងទៀតដោយសារតែភូមិពាមក្រសោបចាស់ ឬភូមិមួយ ជាតំបន់លិចទឹក កុមារគ្រប់អាយុចូលរៀនជាច្រើនមិនបានទទួលការសិក្សារៀនសូត្រ ដោយហេតុខ្វះមធ្យោបាយធ្វើដំណើរ។ កត្តានេះ ជាឧបសគ្គធំសម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងការអប់រំក្រៅប្រព័ន្ធផ្សេងៗ។ មិនតែប៉ុណ្ណោះ កង្វះមធ្យោបាយធ្វើដំណើរ ជាបញ្ហាប្រឈមផងដែរ នៅពេលដែលមានអ្នកជំងឺត្រូវដឹកទៅមន្ទីរពេទ្យស្រុកឬខេត្ត។ ក្រៅពីបញ្ហាការអប់រំ បញ្ហាកង្វះដីសង់លំនៅស្ថាន និងកង្វះដីធ្វើស្រែចំការជាបញ្ហាប្រឈមដែលកើតមានក្នុងស្រុក ហើយក៏ជាឫសគល់ជំរុញឱ្យមានការបង្កើតជាសហគមន៍ឃុំពាមក្រសោបឡើង។

ការរៀបចំបង្កើតសហគមន៍ឃុំពាមក្រសោប ត្រូវបានរៀបចំឡើងជាដំណាក់កាល ដូចខាងក្រោម៖

- លើកទី១៖ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០១ ការជួបជុំមួយ បានរៀបចំឡើងដោយមានការចូលរួមពីគណៈកម្មការ៧រូប និងសមាជិកចូលរួម ចំនួន ៩៧គ្រួសារ ស្មើនឹង១៧៤នាក់។
- លើកទី២៖ ថ្ងៃទី០៣ ខែ តុលា ឆ្នាំ២០០៥ មានការរៀបចំបង្កើតគណៈកម្មការបោះឆ្នោត ដែលមានគណៈកម្មការ១១រូប ក្នុងនោះស្រី០២រូប និងប្រជាពលរដ្ឋចូលរួមចំនួន ២២៨គ្រួសារ ស្មើនឹង១ ០៦៧នាក់។
- ក្នុងដំណាក់កាលនេះ បែបបទរដ្ឋបាលត្រូវបានរៀបចំឡើង ដោយការធ្វើលក្ខន្តិកៈសហគមន៍ ផែនទីសម្រាប់សហគមន៍ និងផែនការសម្រាប់គ្រប់គ្រងសហគមន៍ជាដើម។ ក្រៅពីនេះ ក៏មានការរៀបចំសំណើគាំទ្រពីអាជ្ញាធរដែនដី និងស្ថាប័នជំនាញពាក់ព័ន្ធ លើគម្រោងការនៃការបង្កើតសហគមន៍ពាមក្រសោបដែលមានទីតាំងស្ថិតនៅក្នុងភូមិបាងកាយ៉ាក ឃុំពាមក្រសោប ស្រុកមណ្ឌលសីម៉ា។
- លើកទី៣៖ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៤ គណៈកម្មការសហគមន៍សរុប០៧រូប ក្នុងនោះស្រីចំនួន០១រូប

ត្រូវបានជ្រើសរើសជាតំណាងប្រជាជនក្នុងសហគមន៍ពាមក្រសោប។

សហគមន៍ពាមក្រសោប បានរៀបចំ និងអនុវត្តផែនការសកម្មភាពមួយចំនួន សម្រាប់ជាប្រយោជន៍របស់សហគមន៍ ដូចជា៖ សកម្មភាពយាមល្បាត សកម្មភាពនៃការដាំនិងស្តារព្រៃកោងកាងលើផ្ទៃដីដែលរេចរិល ការគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព ការទប់ស្កាត់បទល្មើសនេសាទ ការបង្កើតឱកាសការងារឱ្យកសិករ និងការបង្កើតកន្លែងចិញ្ចឹមខ្យងជាដើម។

ការងារទាំងអស់នេះ មានទទួលបានការគាំទ្រ និងចូលរួមពីមជ្ឈដ្ឋានអង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធ សមាគមន៍បរិស្ថានកម្ពុជា កម្មវិធីសិលា និងមន្ទីរបរិស្ថានខេត្ត ជាដើម។ ស្ថាប័នពាក់ព័ន្ធទាំងនេះ បានចូលរួមជួយផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីសារប្រយោជន៍ព្រៃកោងកាង និងការដាំកោងកាងឡើងវិញ បន្សាំនិងការបម្រែបម្រួលអាកាសធាតុ ការការពារធនធានធម្មជាតិ។ ក្រៅពីនេះក៏មានសកម្មភាពមនុស្សធម៌ជាច្រើន ត្រូវបានផ្តើមធ្វើដូចជា៖ ផ្តល់ធុងទឹកសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ និងជួយរៀបចំការអភិវឌ្ឍទេសចរណ៍ធម្មជាតិ។ កត្តាទាំងអស់នេះ បានជួយគាំទ្រដល់

លទ្ធភាពនៃការរស់នៅប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជននៅតំបន់ពាមក្រសោបឱ្យមានជីវភាពល្អប្រសើរជាងមុន។

តែទោះជាយ៉ាងណា ក៏នៅតែមានបញ្ហាប្រឈមមួយចំនួន ដែលប្រជាជនក្នុងឃុំពាមក្រសោប ក៏ដូចជានៅក្នុងសមគមន៍ពាមក្រសោប កំពុងជួបប្រទះ ដូចខាងក្រោម៖

- កង្វះភ្លើងអគ្គិសនី កង្វះទឹកប្រើប្រាស់និងទឹកស្អាត
- កង្វះមុខរបរសម្រាប់ចិញ្ចឹមជីវិត
- ទីតាំងអភិវឌ្ឍន៍មិនអំណោយផលដោយសារការបាក់ប្រាំងដោយសាររលក ការហូរច្រោះដីប្រាំងសមុទ្រ ជាបញ្ហាប្រឈមដែលជះឥទ្ធិពលដល់សមិទ្ធិផលនិងមិនមាននិរន្តរភាព
- ការលួចនេសាទខុសច្បាប់ក្នុងសហគមន៍
- កង្វះសាលារៀនសម្រាប់សិស្សរស់នៅតាមបណ្តាកោះ
- បញ្ហាចំណាកស្រុកខុសច្បាប់
- បញ្ហាថវិការអភិវឌ្ឍភូមិឃុំរបស់រដ្ឋតិច
- ការបន្តតាំងទីលំនៅក្នុងភូមិពាមក្រសាបចាស់ឆ្ងាយពីប្រាំងសមុទ្រ
- ការកាប់បំផ្លាញព្រៃឈើខុសច្បាប់
- ការនេសាទដោយខុសច្បាប់ក្នុងដែននេសាទរបស់សហគមន៍។



រូបទី១០៖សកម្មភាពក្រុមការងារចុះសម្ភាសប្រជានេសាទពីស្ថានភាព
នេសាទ នៅឃុំពាមក្រសោបចាស់ ថតថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥



រូបទី១១៖ សកម្មភាពក្រុមការងារសម្ភាសប្រជាជនពីស្ថានភាពរស់នៅ នៅ
ឃុំពាមក្រសោបចាស់ ថតថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥

## សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវមកបានបង្ហាញឱ្យឃើញថា៖ ខេត្តកោះកុងគឺជាខេត្តមួយដែលសម្បូរទៅដោយភ្នំ សមុទ្រ ទន្លេ ព្រៃកនិងកោះជាច្រើន ហើយតំបន់ទាំងនោះពិតជាផ្តល់លក្ខណៈងាយស្រួល និងជាទីជម្រកដ៏ល្អសម្រាប់ការរស់នៅរបស់ជីវៈចម្រុះជាច្រើនប្រភេទ។ តែទោះជាយ៉ាងណាសកម្មភាពនៃការកាប់បំផ្លាញព្រៃឈើ និងការរានដីដើម្បីសង់លំនៅនិងធ្វើកសិកម្មបានក្លាយជាកត្តាគំរាមកំហែងយ៉ាងខ្លាំងដល់ប្រភពធនធានធម្មជាតិ។ តំបន់ព្រៃកោងកាងតាមមាត់សមុទ្រនៃតំបន់ឆ្នេរនៅខេត្តកោះកុង កំពុងរងផលប៉ះពាល់ដោយសារកត្តាពីរយ៉ាងគឺ៖កត្តាមនុស្ស និង កត្តាអាកាសធាតុ។ បច្ចុប្បន្ននេះ ការខូចខាតព្រៃកោងកាងដោយសារកត្តាមនុស្សមានការថយចុះច្រើន ប៉ុន្តែទោះជាយ៉ាងណា កត្តាអាកាសធាតុនៅតែជាបញ្ហាប្រឈម ដែលនាំឱ្យមានផលប៉ះពាល់ខ្លាំងដល់ព្រៃកោងកាង ដោយសារការបម្រែបម្រួលអាកាសធាតុ ធ្វើឱ្យឆ្នេរត្រូវរងនូវសំណឹករេចរិល ហើយក៏ជះឥទ្ធិពលដល់ការលូតលាស់របស់ព្រៃកោងកាងផងដែរ។ ការបាត់បង់ព្រៃជាជម្រករបស់ពួកជីវៈចម្រុះ បានធ្វើឱ្យទឹកប្រៃក្លាយទៅជាពណ៌ក្រហមក្តាម បង្គា ត្រី ខ្យង និងប្រភេទសត្វផ្សេងៗទៀតដែលរស់នៅតាមព្រៃកោងកាងមិនអាចអាស្រ័យនិងបន្តពូជបាន។ ស្ថាន

ភាពទាំងនេះបានបង្កការលំបាក និងប៉ះពាល់យ៉ាងខ្លាំង ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលពឹងអាស្រ័យលើរបរនេសាទ ។ មូលហេតុចំបងដែលជំរុញឱ្យមានសកម្មភាពបំផ្លាញតំបន់ព្រៃកោងកាង និងធនធានសមុទ្រទាំងនេះគឺពាក់ព័ន្ធទៅលើកម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋម្ចាស់ស្រុកនិងអ្នកចំណូលថ្មី ពីព្រោះពួកគាត់មិនបានយល់ពីសារៈប្រយោជន៍ព្រៃកោងកាង ដែលជាប្រភពចំណី និងទីជម្រកសម្រាប់ការរស់នៅរបស់សត្វគ្រប់ប្រភេទដូចជា ពួកបក្សី ថនិកសត្វ និងពួកមច្ឆាជាតិជាដើម មិនត្រឹមតែប៉ុណ្ណោះ វាជារបាំងការពារខ្យល់ផងដែរ។ ដូច្នេះសម្រាប់ការអភិរក្សប្រភេទជីវៈចម្រុះនៅតំបន់ឆ្នេរទាមទារឱ្យមានកិច្ចសហការពីស្ថាប័នរដ្ឋាភិបាល ស្ថាប័នដែលពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍នេសាទ ដើម្បីចូលរួមចំណែកជួយថែរក្សា និងការពារប្រភពធនធានធម្មជាតិទាំងនេះ។

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ប្រភេទសត្វដែលគេបានស្គាល់ និងសត្វទទួលរងគ្រោះ ឬ សត្វដែលទំនងជានៅមានរស់រានក្នុងដែនជម្រកសត្វព្រៃពាមក្រសោប នៃខេត្តកោះកុង

| ល.រ | ឈ្មោះ ភាសាខ្មែរ | ឈ្មោះ ភាសាអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | រូបភាព * |
|---|---|---|---|---|
| I. | ថនិកសត្វ | **Mammals** | | |
| ១ | សត្វស្វាក្តាម | Long-tailed macaque | Macaca fascicularis |  |
| ២ | សត្វសំពោច | Civet sp.** | 'Viverridae' family |  |

| | | | | |
|---|---|---|---|---|
| ៣ | សត្វជ្រឹង | Flying fox sp.** | Pteropus vampyrus,<br>P. lylei,<br>P. hypomelanus |  |
| ៤ | សត្វជ្រូកព្រៃ | Wild Pig | Sus scrofa |  |
| ៥ | សត្វក្ដាន់ព្រៀង | Mouse deer sp.** | 'Tragulidae' family |  |

| | | | | |
|---|---|---|---|---|
| ៦ | សត្វឈ្លូស | Red muntjac | Muntiacus muntjak |  |
| ៧ | សត្វប្រើស | Sambar deer | Cervus unicolor or Rusa unicolor |  |
| ៨ | សត្វទន្សាយ | Hare sp.** | 'Leporidae' family |  |
| ៩ | សត្វកំប្រុក | Squirrel sp.** | 'Sciuridae' family |  |

| | | | | |
|---|---|---|---|---|
| ១០ | សត្វខ្លាត្រី | Fishing cat | Prionailurus viverrinus |  |
| ១១ | អំបូរសត្វភេ | Otter sp.** | Lutra sp.** |  |
| ១២ | អំបូរត្រីដុលហ្វីន/ សត្វផ្សោត | Dolphin sp.** | |  |
| ១៣ | សត្វខ្លាធំ | Tiger | Panthera tigris |  |
| ១៤ | សត្វជ្រូកពោន | Hog badger | Arctonyx collaris |  |

| | | | | |
|---|---|---|---|---|
| ១៥ | អំបូរសត្វទោច | Gibbon sp.** | Hylobates sp.** |  |
| ១៦ | សត្វស្វាគ្រោស | Northern pig-tailed macaque | Macaca leonine |  |
| ១៧ | សត្វឆ្កែព្រៃ | Dhole | Cuon alpinus |  |
| ១៨ | សត្វរញ៉ី | Loris sp.** | Nycticebus sp.** |  |
| ១៩ | សត្វពង្រូល | Sunda pangolin | Manis javanica |  |

| | | | | |
|---|---|---|---|---|
| ២០ | សត្វខ្លាឃ្មុំ | Bear sp.** | Ursus sp.** |  |
| ២១ | សត្វខ្លាពពក | Clouded leopard | Neofelis nebulosa |  |
| ២២ | សត្វឆ្មាព្រៃ | Jungle cat | Felis chaus |  |
| ២៣ | សត្វប្រមា | East asian porcupine | Hystrix brachyuran |  |
| ២៤ | សត្វស្វាព្រាម | Silver langur | Trachypithecus germaini |  |
| | | | | |

| II. | សត្វបក្សី | **Birds** | | |
|---|---|---|---|---|
| ១ | សត្វកុក | Egret sp.** | 'Ardeidae' family |  |
| ២ | សត្វមាន់ទឹក | White-breasted waterhen | Amaurormis Phoenicurus |  |
| ៣ | សត្វចចាតក្រឹម | Common kingfisher | Alcedo atthis |  |
| ៤ | សត្វទុងប្រផេះ | Spot-billed pelican | Pelecanus philippensis |  |

| | | | | |
|---|---|---|---|---|
| ៥ | សត្វក្អែក | Corvus or Crow sp.** | 'Corvidae' family |  |
| ៦ | សត្វទីទុយ | Owl sp.** | Strigiformes |  |
| ៧ | សត្វរំពេរ | Tern sp.** (greater crested tern) | Sternidae (Thalasseus bergii) |  |
| ៨ | សត្វក្លុំ | Water cock | Gallicrex cinerea |  |

| | | | | |
|---|---|---|---|---|
| ៩ | សត្វក្រួច | Bottonquail | Turnicidae |  |
| ១០ | សត្វទាព្រៃ | Garganey | Anas querquedula |  |
| ១១ | សត្វពពូល | Green imperial pigeon | Ducula aenea |  |
| ១២ | សត្វសេក | Parrot sp.** | 'Psittacoidea' family |  |

| | | | | |
|---|---|---|---|---|
| ១៣ | សត្វលលក | Dove[11] sp.** | 'Columbidae' family |  |
| ១៤ | សត្វសារិកាកែវ | Common hill myna | Gracula religiosa |  |
| ១៥ | សត្វមាន់ព្រៃ | Red junglefowl | Gallus gallus |  |

[11] សត្វលលកមានចំនួន ៦ប្រភេទផ្សេងគ្នានៅក្នុងប្រទេសកម្ពុជា (https://en.wikipedia.org/wiki/List_of_birds_of_Cambodia)។

| | | | | |
|---|---|---|---|---|
| ១៦ | សត្វខ្លែងស្រាក | Barn owl | Tyto alba |  |
| ១៧ | សត្វខ្លែងឆាបលឿងក្រម៉ៅ | Brahminy kite | Haliastur indus |  |
| ១៨ | សត្វប្រវឹក | Lesser whistling duck | Dendrocygna javanica |  |
| ១៩ | សត្វត្រដក់ | Leptoptilos or Storks sp.** | 'Ciconiidae' family |  |
| ២០ | សត្វត្រយ៉ងយក្ស | Giant ibis | Pseudibis gigantean/ Thaumatibis gigantea |  |

| | | | | |
|---|---|---|---|---|
| ២១ | សត្វអកសមុទ្រ | White-bellied sea eagle | Haliaeetus leucogaster |  |
| ២២ | សត្វឥន្ទ្រី | Imperial eagle | Aquila heliaca |  |
| ២៣ | សត្វក្រៀល | Sarus crane | Grus antigone |  |
| ២៤ | សត្វនោល | Mycteria sp. or Stork sp.** | 'Ciconiidae' family |  |
| ២៥ | អំបូរសត្វកេងកង | Hornbill sp.** | 'Bucerotidae' family |  |

| | | | | |
|---|---|---|---|---|
| | | | |  |
| ២៦ | សត្វញាំង | Wreathed hornbill | Aceros undulates/ Rhyticeros undulatus |  |
| ២៧ | សត្វក្ងោក | Green peafowl | Pavo muticus |  |
| III. | ឧរង្គសត្វ | **Reptiles** | | |
| ១ | សត្វពស់ថ្លាន់ | Python sp.** | 'Pythonidae' family |  |

| | | | | |
|---|---|---|---|---|
| ២ | សត្វពស់វែក | King cobra | Ophiophagus hannah |  |
| ៣ | សត្វអណ្តើក | Turtle sp.* | Testudines or Chelonii |  |
| ៤ | សត្វទន្សង | Water monitor | Varanu salvator |  |
| ៥ | សត្វត្រកួត | Bengal monitor | Varanu bengalensis |  |
| ៦ | សត្វកន្ធាយ | Soft-shelled turtle sp.* | 'Trionychidae' family |  |

| | | | | |
|---|---|---|---|---|
| ៧ | សត្វអណ្តើកក្អែក | Common musk turtle | Sternotherus odoratus |  |
| ៨ | សត្វអណ្តើកសកល | Yellow-headed temple turtle | Heosemys annandalii |  |
| ៩ | សត្វអណ្តើកទឹក | Asian leaf turtle | Cyclemys dentata |  |
| ១០ | សត្វអណ្តើកស្រែ | Malayan snail-eating turtle | Malayemys macrocephala |  |

<u>កំណត់សំគាល់៖</u> * : រូបភាពបន្ថែម បានពី Google Images,

** : គ្មានការកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ ហើយរូបភាពដែលមានក្នុងចំណុចនេះ គឺជារូបភាពតំណាងឱ្យប្រភេទពូជសត្វ

ឧបសម្ព័ន្ធទី២៖ ប្រភេទដែនជម្រកសត្វដែលគេបានស្គាល់ ដែលនៅមានក្នុងដែនជម្រកសត្វព្រៃពាម
ក្រសោប នៃខេត្តកោះកុង

| ល.រ | ឈ្មោះភាសាខ្មែរ | ឈ្មោះភាសាអង់គ្លេស |
|---|---|---|
| ១ | ព្រៃកោងកាង | Mangrove forest |
| ២ | ព្រៃស្រោង | Evergreen forest |
| ៣ | ព្រៃស្មាច់ | Smach forest ( Melaleuca Leuca dandraon ) |
| ៤ | ព្រៃស្មែរ | Sme forest ( Aegialites rotundefolia ) |
| ៥ | ព្រៃប្រសាក់ | Brasac forest ( Rhizophoraceae ) |
| ៦ | ព្រៃស្ងាវ | Sngaw forest ( type of pine forest ) |
| ៧ | ព្រៃក្រញឹប | Kranheb forest ( Combretaceae ) |
| ៨ | ព្រៃឫស្សី | Bamboo forest |
| ៩ | ព្រៃក្បាញ | Khbanh forest ( some villagers called Krovanh ) |

( ប្រភព៖ An et al. ( 2009 ) )

ឧបសម្ព័ន្ធទី៣៖ តំបន់គ្រប់គ្រងទាំងបួនក្នុងតំបន់ការពារ ដោយផ្អែកលើច្បាប់នៃតំបន់ការពារនៃក្រសួងបរិស្ថានក្នុងឆ្នាំ២០០៨

| ប្រភេទនៃតំបន់ | អត្ថន័យ |
| --- | --- |
| ១. តំបន់ស្នូល | តំបន់គ្រប់គ្រងដែលមានតម្លៃនៃការអភិរក្សកម្រិតខ្ពស់មានប្រភេទសត្វដែលកំពុងរងគ្រោះថ្នាក់ខ្លាំង និងកំពុងរងការគំរាមកំហែង ហើយនិងប្រព័ន្ធអេកូឡូស៊ីដែលផុយស្រួយ។ |
| ២. តំបន់អភិរក្ស | តំបន់គ្រប់គ្រងដែលមានតម្លៃនៃការអភិរក្សកម្រិតខ្ពស់មានប្រភពធនធានធម្មជាតិច្រើន, ប្រព័ន្ធអេកូឡូស៊ី, តំបន់ទីជម្រាល, និងទីធម្មជាតិដែលស្ថិតនៅក្បែរតំបន់ស្នូល។ |
| ៣.តំបន់ប្រើប្រាស់ដោយ | តំបន់គ្រប់គ្រងដែលមានតម្លៃនៃការអភិរក្សកម្រិតខ្ពស់សម្រាប់ |

| | |
|---|---|
| ជីវភាព | ការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងការគ្រប់គ្រង និងការអភិរក្សតំបន់ការពារ ដែលនឹងចូលរួមចំណែកជួយដល់សហគមន៍ក្នុងស្រុក និងការកែលំអកម្រិតជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចនានា។ |
| ៤. តំបន់សហគមន៍ | តំបន់គ្រប់គ្រងសម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចនៃសហគមន៍ក្នុងស្រុក និងជនជាតិដើមភាគតិចនានា ហើយអាចរួមបញ្ចូលនូវដីសង់ទីលំនៅ, វាលស្រែ, និងសួនបន្លែ ឬ ចម្ការដំណាំកសិកម្ម។ |

(ប្រភព៖ របាយណ៍ការថ្នាក់ជាតិនៃច្បាប់តំបន់ការពារនៃប្រទេសកម្ពុជា ក្រសួងបរិស្ថាន ឆ្នាំ២០០៨)

ឧបសម្ព័ន្ធទី៤៖ តារាងឈ្មោះប្រភេទព្រៃកោងកាង

| ល.រ | ឈ្មោះភាសាខ្មែរ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | រូបភាព |
|---|---|---|---|---|
| ១ | ដើមត្រចៀកក្រាញ់ ឬ ដើមត្រចៀកក្រាញ់ស្លឹកធម្មតា | Acanthus; Sea holly[a] | *Acanthus ebracteatus* |  |
| ២ | ដើមត្រចៀកក្រាញ់ស្លឹកឆែក ឬ ដើមត្រចៀកក្រាញ់ស្លឹកបន្លា | Holly mangrove[a,c] | *Acanthus ilicifolius* |  |
| ៣ | ដើមប្រង់ ឬ ដើមប្រង់សមុទ្រ | Golden leather fern[a,c] | *Acrostichum aureum* |  |

| | | | | |
|---|---|---|---|---|
| ៤ | ដើមប្រង់ ឬ<br>ដើមខ្នាញ់ | Mangrove fern[a,c] | Acrostichum speciosum |  |
| ៥ | ដើមក្រចកដៃនាង | n/a | Aegiceras floridum |  |
| ៦ | ដើមក្បាញស ឬ<br>ដើមស្មាន ឬ<br>ដើមមួយរយស្រទាប់ | Api-api[d] | Avicennia alba |  |

| | | | | |
|---|---|---|---|---|
| ៧ | ដើមក្បាញ ឬ<br>ដើមស្លង់ ឬ<br>ដើមមួយរយស្រទាប់ | Gray Mangrove[a,c]<br>White Mangrove[d] | Avicennia marina |  |
| ៨ | ដើមក្បាញខ្មៅ ឬ<br>ដើមស្លង់ | Indian mangrove[c] | Avicennia officinalis |  |
| ៩ | ដើមបាសាក់ស | n/a | Bruguiera cylindrica |  |
| ១០ | ដើមបាសាក់ក្រហម | Burmese Mangrove[a] | Bruguiera gymnorrhiza |  |

| | | | | |
|---|---|---|---|---|
| ១១ | ដើមបាសាក់ស ឬ ដើមរំពួង | Oriental mangrove[a,d] | Bruguiera sexangula |  |
| ១២ | ដើមពិលពេជ្រ ឬ ដើមជើងទា ឬ ដើមជំពូព្រៃ | Pong-pong[a]<br>a member of Dogbanes (Family Apocynaceae)[c] | Cerbera odollam |  |
| ១៣ | ដើមស្មែស | Yellow mangrove[a] | Ceriops decandra |  |

| | | | | |
|---|---|---|---|---|
| ១៤ | ដើមស្មែក្រហម | Yellow Mangrove[a] | Ceriops tagal |  |
| ១៥ | ដើមម្លូជ្វា ឬ<br>ដើមអម្រែកក្តាន់ | Scrambling[a]<br>Clerodendrum[a]<br>Harmless[a];<br>Clerodendron[b] | Clerodendrum inerme |  |
| ១៦ | វល្លិ៍ប្រេងសមុទ្រ | Threeleaf Derris[a,b] | Derris trifoliata |  |

| | | | | |
|---|---|---|---|---|
| ១៧ | ដើមឈើជ័រ ឬ ដើមតាទុំ | Milky Mangrove[a,b,c] | Excoecaria agallocha |  |
| ១៨ | វល្លិពោះត្រី | n/a | Finlaysonia maritima |  |
| ១៩ | វល្លិ រេ ឬ ផ្តៅអណ្តើក ឬផ្តៅស្វា | n/a | Finlaysonia indica | n/a |
| ២០ | ដើមសិរមាន់សមុទ្រ ឬ ដើមសិរមាន់ទឹកប្រៃ | Looking Glass Tree[a,b]; Red/Tulip Mangrove[b] | Heritiera littoralis |   |

| | | | | |
|---|---|---|---|---|
| ២១ | ដើមបើស ឬ ដើមកប្បាស់ព្រៃទឹកប្រៃ | Hawaii Sea-hibiscus[a]<br>Sea-hibiscus[c] | Hibiscus tiliaceus Or Talipariti tiliaceum[a] | <br> |
| ២២ | ដើមកកោះទឹកប្រៃ ឬ ដើមក្រញូងទឹកប្រៃ ឬ អំពារឈ្មោល | Moluccan ironwood[a]; Ipil[c]; Pacific Teak; Scrub mahogany; Kwila[b] | Intsia bijuga |  |
| ២៣ | វល្លិត្រកួនកន្ទែកសមុទ្រ | Railroad-vine[d] | Ipomoea pes-caprae |  |
| ២៤ | ដើមក្រញឹបក្រហម | Black mangrove[c] | Lumnitzera littorea |  |

| | | | | |
|---|---|---|---|---|
| ២៥ | ដើមក្រញ៉ីបស | Kripa[d]<br>White-flowered black mangrove[c] | Lumnitzera racemosa |  |
| ២៦ | ដើមចាក | Nypa Palm[d]<br>Mangrove Palm[c] | Nypa fruticans | <br> |
| ២៧ | ដើមរំចេកសមុទ្រ | Beach Pandan[a]<br>Thatch Srewpine[c] | Pandanus tectorius | <br> |

| | | | | |
|---|---|---|---|---|
| ២៨ | ដើមប៉ឹង | Mangrove date palm | Phoenix paludosa |  |
| ២៩ | ដើមព្រះអន្លក់ | Indian Camphorweed[a] | Pluchea indica |  |
| ៣០ | ដើមកោងកាងស្លឹកតូច | Tall-stilted Mangrove[c] | Rhizophora apiculata |  |
| ៣១ | ដើមកោងកាងស្លឹកធំ | Indo-West Pacific stilt mangrove[c] | Rhizophora mucronata |  |

| | | | | |
|---|---|---|---|---|
| | | | |  |
| ៣២ | ដើមស្លឹក ត្រចៀកប្រើសសមុទ្រ | Beach Naupaka[d]<br>Sea lettuce[c] | Scaevola taccada |  |
| ៣៣ | ដើមក្រញឹបឈ្មោល | n/a | Scyphiphora hydrophylacea |  |
| ៣៤ | ស្មៅអណ្តាតពស់ | Sea purslane[c,d] | Sesuvium portulacastrum |  |

| | | | | |
|---|---|---|---|---|
| ៣៥ | ដើមអំពូល ឬ<br>ដើមអំពូលថ្ម | Apple mangrove[c]<br>Mangrove apple[d] | Sonneratia alba |  |
| ៣៦ | ដើមអំពូល ឬ<br>ដើមអំពូលក្រហម | Apple mangrove[c];<br>Crabapple mangrove[d] | Sonneratia caseolaris |  |
| ៣៧ | ដើមអំពារ | a member of Myrtales<br>(Order Myrtales)[c] | Sonneratia ovata |  |
| ៣៨ | ដើមពោធិ៍សមុទ្រ ឬ<br>ដើមកប្បាស់ទឹកប្រៃ | Portia tree[c,d] | Thespesia populnea |  |

| | | | | |
|---|---|---|---|---|
| ៣៩ | ដើមកន្រ្ទានខែត្រ សមុទ្រ | Sea daisy[c,d], Beach daisy[c], Sea ox-eye[e] | Wedelia biflora or Melanthera biflora |  |
| ៤០ | ដើមតាប៉ុនស | Cannonball mangrove[c] | Xylocarpus granatum |   |
| ៤១ | ដើមតាប៉ុនខ្មៅ | Cedar mangrove[d] | Xylocarpus moluccensis |  |

កំណត់សំគាល់៖ [a]: IUCN redlist (www.iucnredlist.org)

[b]: Australian Tropical Rainforest Plants (http://keys.trin.org.au/key-server/data/0e0f0504-0103-430d-8004-060d07080d04/media/Html/taxon/index.htm)

[c] :iNaturalist.org (http://www.inaturalist.org/taxa/47126-Plantae)

[d] : Encyclopedia of Life (http://eol.org)

[e] : The Free Wikipedia

## ឯកសារយោងនិទ្ទេស

ក. ភាសាជាតិ

១. ក្រសួងបរិស្ថាន *របាយណ៍ការថ្នាក់ជាតិស្តីពីច្បាប់តំបន់ការពារនៃប្រទេសកម្ពុជា* ភ្នំពេញ កម្ពុជា ឆ្នាំ២០០៨។

២. ក្រសួងបរិស្ថាន *របាយការណ៍ស្ថានភាពបរិស្ថាន* ភ្នំពេញ កម្ពុជា ឆ្នាំ២០០៤។

៣. ក្រសួងបរិស្ថាន *មូលដ្ឋានគ្រឹះនៃបរិស្ថាន* ភ្នំពេញ កម្ពុជា ឆ្នាំ២០០៤។

៤. ក្រសួងបរិស្ថាន *មូលដ្ឋានគ្រឹះនៃបរិស្ថាន* ភ្នំពេញ កម្ពុជា ឆ្នាំ២០០៦។

៥.ក្រសួងអប់រំ *ឯកសារការអប់រំបំណិនជីវិតស្តីពីបរិស្ថាន* នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ភ្នំពេញ កម្ពុជា ឆ្នាំ២០១៣។

៦. មន្ទីរបរិស្ថាន *របាយការណ៍បរិស្ថានខេត្តកោះកុង* ខេត្តកោះកុង ឆ្នាំ ២០១៣

៧. ធនាគារអភិវឌ្ឍន៍អាស៊ី *ការគ្រប់គ្រងបរិស្ថានសមុទ្រ និងតំបន់ឆ្នេរសមុទ្រចិនខាងត្បូង ភាគទី១* ភ្នំពេញ កម្ពុជា ខែតុលា ឆ្នាំ១៩៩៩។

៨. ធនាគារអភិវឌ្ឍន៍អាស៊ី *ការគ្រប់គ្រងបរិស្ថានសមុទ្រ និងតំបន់ឆ្នេរក្នុងសមុទ្រចិនខាងត្បូង ភាគទី២* ទំព័រទី៣ ភ្នំពេញ កម្ពុជា ខែតុលា ឆ្នាំ១៩៩៩។

៩. លោកយ៉ែម យ៉ាន បទបង្ហាញស្តីពី *សហគមន៍តំបន់ការពារធម្មជាតិ និងនេសាទឃុំពាមក្រសោប* ទំព័រទី២ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១០។

## ខ. ភាសាបរទេស

10. AN, D., KONG, K., HUOT, P. & MATHER, R. 2009. An Integrated Assessment for Preliminary Zoning of Peam Krasop Wildlife Sanctuary, Southwestern Cambodia.

11. ASHWELL, D. 1998. Conservation issues and information Requirements. *Phnom Penh, Cambodia: the World Bank.*

12. BEASLEY, I. & DAVIDSON, P. 2007. Conservation status of marine mammals in Cambodian waters, including seven new cetacean records of occurrence. *Aquatic Mammals,* 33, 368-379.

13. CDC. 2015. Koh Kong Province. *Provincial Data* [Online]. Available: http://www.cambodiainvestment.gov.kh/koh-kong-province.html [Accessed 16 June 2015].

14. COLIN, M. P., ANDREW, W. T., DAVIDSON, P., & DELATTRE, E. 2003. The department of nature conservation and protection birdlife international in

Indochina wildlife conservation society Cambodia program with financial support from Danida.

15. HOUT, S. K., BUNNAT, P., POOLE, C., TORDOFF, A., DAVIDSON, P. & DELATTRE, E. 2003. Directory of Important Bird Areas in Cambodia: key sites for conservation. *Phnom Penh: Wildlife Conservation Society*.

16. NIS. 2009. General Population Census of Cambodia 2008: National Report on Final Census Results. *Ministry of Planning, UNFPA, JICA, Phnom Penh.* Available: http://camnut.weebly.com/uploads/2/0/3/8/20389289/2009_census_2008.pdf [Accessed 09 July 2015].

17. NIS. 2013. Economic Census of Cambodia 2011: Provincial Report 09 Koh Kong Province. *Ministry of Planning, UNFPA , JICA, Phnom Penh.* Available: http://www.jica.go.jp/cambodia/office/information/investment/ku57pq00001vq919-att/state_09.pdf [Accessed 01 July 2015].

18. PHON, D. 2000. Dictionary of Plants used in Cambodia. *Imprimerie Olympic, Phnom Penh*.

19. RIZVI, A. R. & SINGER, U. 2011. *Cambodia Coastal Situation Analysis*, Gland, Switzerland: IUCN.

20. SMITH, J. 2001. Biodiversity, the life of Cambodia. *Cambodia's Biodiversity Status Report–2001. Ministry of Environment, UNDP, GEF & FAO, Phnom Penh*.

21. WHARTON, C. H. 1966. Fire and Wild Cattle in North Cambodia. Proceedings 5th. Annual Tall Timber Fire Ecology Conference, 23-65.



រៀបរៀង និង បោះពុម្ពផ្សាយលើទី១
ផ្នែកបរិស្ថានធម្មជាតិ និង ជីវវិទ្យា